គម្រោងផ្តល់សេវាកម្មបរិស្ថាន
ប្រកបដោយចីរភាព

SPES

SUSTAINABLE PROVISION *of* ECOSYSTEM SERVICES

# សៀវភៅបណ្តុះបណ្តាលស្តីពី
# ការគ្រប់គ្រងធនធានធម្មជាតិ



រៀបចំដោយ៖ វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល
គាំទ្រថវិកាដោយ៖ សហភាពអឺរ៉ុប តាមរយៈអង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិ

សហភាពអឺរ៉ុប

FAUNA & FLORA INTERNATIONAL

THE LEARNING INSTITUTE
People and Natural Resources

លេខ១
កក្កដា
២០១២

# បុព្វកថា

គម្រោងផ្ដល់សេវាកម្មបរិស្ថានប្រកបដោយចីរភាព[1] គឺជាគម្រោងដែលទទួលបានការគាំទ្រ មូលនិធិពីសំណាក់សហភាពអឺរ៉ុប (EU) តាមរយៈអង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិ (FFI) ដើម្បីអនុវត្ត សាកល្បងនៅក្នុងខេត្តពោធិ៍សាត់ និងកោះកុង។ វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្ដុះបណ្ដាល (The Learning Institute) គឺជាដៃគូសហការសម្រាប់ការអនុវត្តគម្រោងនេះ ក្នុងផ្នែកបង្កើនការយល់ដឹងអំពី ការផ្ដល់នូវនិរន្តរភាពសេវាកម្មបរិស្ថាន នៅតំបន់ជួរភ្នំក្រវាញទៅដល់បណ្ដាអ្នកពាក់ព័ន្ធ ជាពិសេសអាជ្ញាធរ និងសហគមន៍មូលដ្ឋាន។ នៅចុងឆ្នាំ ២០១១ និងដើមឆ្នាំ ២០១២ ក្រុមការងារគម្រោងការផ្ដល់នូវសេវាកម្ម បរិស្ថានប្រកបដោយនិរន្តរភាពរបស់វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្ដុះបណ្ដាលបានរៀបចំឲ្យមាននូវសិក្ខាសាលាស្ដីពី ការប៉ាន់ប្រមាណតម្រូវការវគ្គបណ្ដុះបណ្ដាលឡើងនៅក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់ និងស្រុកថ្មបាំង ខេត្តកោះកុង។ បន្ទាប់ពីការផ្ទៀងផ្ទាត់លទ្ធផលពីសំណាក់បណ្ដាអ្នកពាក់ព័ន្ធរួចមក ក្រុមការងារគម្រោងបានរកឃើញនូវតម្រូវការជាអាទិភាពដើម្បីរៀបចំជាវគ្គបណ្ដុះបណ្ដាលចំនួនបួន។ តម្រូវការទាំងនោះរួមមាន៖ ១. ការគ្រប់គ្រងធនធានធម្មជាតិ ២. ការប្រាស្រ័យទាក់ទង ការកសាងបណ្ដាញ និងភាពជាដៃគូ ៣. ភាពជាអ្នកដឹកនាំ និងការរៀបចំសហគមន៍ និង ៤. ការកសាងផែនការដោយមានការចូលរួម។ លទ្ធផលទាំងនេះបានត្រូវលើកយកទៅដើម្បីចងក្រងជាមេរៀន និងសម្ភារសម្រាប់បណ្ដុះបណ្ដាលកសាងសមត្ថភាព និង ចំណេះដឹងទៅដល់ក្រុមគោលដៅគម្រោង ដែលក្នុងនោះរួមមានអាជ្ញាធរភូមិឃុំ ក្រុមសមាជិកគណៈកម្មការ និងប្រជាពលរដ្ឋដែលមកពីតំបន់គោលដៅនៅក្នុងខេត្តពោធិ៍សាត់ និងកោះកុង។

ដោយឡែក សៀវភៅមេរៀនស្ដីពីការគ្រប់គ្រងធនធានធម្មជាតិនេះនឹងមានសារៈប្រយោជន៍សម្រាប់ជាជំនួយដល់អ្នករៀនសូត្រដើម្បីស្វែងយល់ពីមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងធនធានធម្មជាតិរបស់ពួកគាត់ ព្រមទាំងទស្សនៈទានជាមូលដ្ឋានមួយចំនួនទៅលើដំណើរការរៀបចំឲ្យមានការផ្ដល់សំណងទៅលើសេវាកម្មបរិស្ថាន ហើយក៏ដើម្បីបង្កើនសមត្ថភាពបន្ថែមទៀតទៅលើចំណេះដឹង និងបទពិសោធន៍ដែលកំពុងតែអនុវត្តជាក់ស្ដែង នៅក្នុងសហគមន៍របស់ខ្លួន។ លើសពីនេះទៅទៀត គឺដើម្បីចែករំលែកចំណេះដឹងលើបច្ចេកទេសមួយចំនួនទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិតាមរយៈការឆ្លុះបញ្ចាំងទៅលើការអនុវត្តការងារបច្ចុប្បន្នរបស់ពួកគាត់ ជាមួយនឹងអ្វីដែលក្រុមអ្នកសម្របសម្រួលរបស់វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្ដុះបណ្ដាលបានចែករំលែកក្នុងវគ្គបណ្ដុះបណ្ដាលផ្ទាល់។

ក្រុមការងារនៃវិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្ដុះបណ្ដាល សង្ឃឹមនិងជឿជាក់យ៉ាងមុតមាំថាអ្នកអនុវត្តការងារពាក់ព័ន្ធទាំងអស់រួមមានស្ថាប័នរដ្ឋ និងអង្គការសង្គមស៊ីវិល ក៏ដូចជាសហគមន៍មូលដ្ឋាននឹងប្រើប្រាស់សៀវភៅមេរៀននេះជាប្រយោជន៍រួមដើម្បីគាំទ្ររាល់ការអនុវត្តការងារប្រចាំថ្ងៃរបស់ខ្លួន បូករួមជាមួយនឹងបទពិសោធន៍ការងារជាក់ស្ដែងនៅមូលដ្ឋានរៀងៗខ្លួន ក៏ដូចជាបន្តការចែករំលែកឲ្យបានទូលំទូលាយផងដែរ។

ក្រុមការងារនៃវិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្ដុះបណ្ដាល យើងខ្ញុំនៅតែមានជំនឿថា សៀវភៅបណ្ដុះបណ្ដាលនេះនឹងនៅតែមានចន្លោះខ្វះខាតជាក់ជាពុំខាន ហើយយើងខ្ញុំក៏សង្ឃឹមផងដែរថាអស់លោក លោកស្រីដែលជាអ្នកប្រើប្រាស់ទាំងអស់នឹងជួយផ្ដល់មតិយោបល់ល្អៗ ដែលបានពីការប្រើប្រាស់ផ្ទាល់ប្រយោជន៍ដើម្បីជួយកែលម្អឱ្យសៀវភៅនេះកាន់តែមានភាពសុក្រឹត និងភាពប្រសើរឡើងសម្រាប់ការបោះពុម្ពលើកក្រោយៗទៀត។

**សូមអរគុណ**

[1] Sustainable Provision of Ecosystem Services (SPES)

# មាតិកា


ទំព័រ

បុព្វកថា i

**ផ្នែកទី ១ ៖ ទស្សនៈទានជាមូលដ្ឋាននៃធនធានធម្មជាតិ**

១.១ និយមន័យ ១

១.២ ប្រភេទនៃធនធានធម្មជាតិ ២

១.២.១ ធនធានធម្មជាតិកើតឡើងវិញ ៣

១.២.២ ធនធានធម្មជាតិមិនកើតឡើងវិញ ៣

១.៣ ប្រព័ន្ធនៃធនធានធម្មជាតិ ៦

១.៤ តម្លៃធនធានធម្មជាតិ ៦

១.៤.១ តម្លៃប្រើប្រាស់ ៧

១.៤.២ តម្លៃជម្រើស ១០

១.៤.៣ តម្លៃអភិរក្ស ១០

**ផ្នែកទី២ ៖ ការគ្រប់គ្រងធនធានធម្មជាតិ**

២.១ សារតានៃការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងប្រទេសកម្ពុជា ១១

២.២ និយមន័យការគ្រប់គ្រងធនធានធម្មជាតិ ១២

២.៣ ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព ១២

២.៣.១ និយមន័យ ១២

២.៣.២ ចំណុចគួរពិចារណាអំពីការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព ១៣

២.៤ ទម្រង់នៃការគ្រប់គ្រងធនធាន ១៤

២.៤.១ ការគ្រប់គ្រងតាមបែបមជ្ឈការ ១៥

២.៤.២ ការគ្រប់គ្រងតាមបែបវិមជ្ឈការ ១៥

២.៤.៣ សហគ្រប់គ្រង ១៧

**ផ្នែកទី ៣ ៖ សំណងលើសេវាកម្មបរិស្ថាន**

៣.១ ទស្សនទាននៃសំណងលើសេវាកម្មបរិស្ថាន ២០

៣.១.១ សំណងលើសេវាកម្មបរិស្ថាន ២០

៣.១.២ ប្រភេទនៃសេវាកម្មបរិស្ថាន ២១

៣.១.៣ ទម្រង់នានានៃសំណងលើសេវាកម្មបរិស្ថាន ២១

៣.១.៤ ដំណាក់កាលនៃការរៀចំសំណងលើសេវាកម្មបរិស្ថាន ២២

៣.១.៥ បទពិសោធន៍នានានៃសំណងលើសេវាកម្មបរិស្ថាន ២៣

សត្វព្រៃ និងរុក្ខជាតិដែលជានិមិត្តសញ្ញាតំណាងឲ្យប្រទេសកម្ពុជា

បទចម្រៀង៖ សំលេងព្រៃអង្គរ

ឯកសារយោង

# ផ្នែកទី ១ ៖ ទស្សនទានជាមូលដ្ឋាននៃធនធានធម្មជាតិ

## ១.១ និយមន័យ

តើធនធានធម្មជាតិជាអ្វី?

ធនធានធម្មជាតិត្រូវបានគេឲ្យនិយមន័យផ្សេងៗគ្នាទៅតាមបរិបទ និងការយល់ឃើញរបស់មនុស្សផ្សេងៗគ្នា ឬក៏ស្ថាប័នក្នុងនោះរួមមាន៖

- តាមវចនានុក្រមបរិស្ថាន និងអភិរក្សរបស់សាកលវិទ្យាល័យអុកហ្វត (Oxford) ឆ្នាំ២០០៨ បានឲ្យនិយមន័យថា "ធនធានធម្មជាតិ គឺជាអ្វីៗដែលជាបរិស្ថានធម្មជាតិមានតម្លៃក្នុងការបំពេញតម្រូវការរបស់មនុស្ស ដោយរួមមានរុក្ខជាតិ ទឹក ដី និងសត្វព្រៃ ប្រេង (ប្រេងកាតសាំង) ឧស្ម័នធម្មជាតិ ថ្មរងថ្ម និងរ៉ែជាដើម។
- ធនធានធម្មជាតិជាអ្វីៗ ដែលកើតឡើងដោយឯកឯងរួមមាន ទឹក ដី ខ្យល់ ព្រៃឈើ ទន្លេ សមុទ្រ ភ្នំពន្លឺព្រះអាទិត្យជាដើម។ល។ ដែលផ្ដល់តម្លៃ និងសារប្រយោជន៍យ៉ាងច្រើន ព្រមទាំងបំពេញសេចក្ដីត្រូវការរបស់មនុស្សជាតិ។

ធនធានធម្មជាតិទាំងនោះបានរួមចំណែកដល់ការអភិវឌ្ឍ ផ្នែករូបសាស្ត្រ ផ្លូវចិត្ត គំនិត ស្មារតី និងសុខមាលភាពរបស់មនុស្ស ហើយមានសារសំខាន់សម្រាប់ទ្រទ្រង់ជីវិតនៃប្រភេទផ្សេងៗទៀតនៅលើផែនដី។

មានពាក្យសំខាន់មួយចំនួនដែលគេតែងតែជួបក្នុងបរិបទ នៃការគ្រប់គ្រងធនធានធម្មជាតិ ពាក្យទាំង នោះមានដូចជា៖

***<u>បរិស្ថាន៖</u>*** គឺជាអ្វីៗដែលស្ថិតនៅជុំវិញខ្លួនយើង ដូចជាទឹកដី ខ្យល់ កម្ដៅ រុក្ខជាតិ សត្វ ព្រមទាំង របស់ផ្សេងៗទៀតដែលមនុស្សបានបង្កើត (អាគារ តុ.......) រួមទាំងខ្លួនយើងផងដែរ។ បរិស្ថានមានពីរសំខាន់ៗ គឺ បរិស្ថាន ធម្មជាតិ និងបរិស្ថានវប្បធម៌-សង្គម។

***<u>ជីវចម្រុះ៖</u>*** គឺជាប្រភេទនៃជីវិតផ្សេងដែលមាននៅលើផែនដី។ ជាទូទៅជីវចំរុះសម្រាប់សម្គាល់ប្រភេទទាំងអស់នៃជីវិតសត្វ រុក្ខជាតិ មីក្រូសារពាង្គកាយ រូបធាតុ សេនេទិច ព្រមទាំងប្រព័ន្ធអេកូឡូស៊ី។ ឧទាហរណ៍ភាពចម្រុះនៃប្រភេទ ដូចជា ដំរី ខ្លា ត្រីរៀល កុក ក្រសា ពស់ថ្លាន់ ទោចជន្លេន ស្រមោច រុក្ខជាតិ ផ្សេងៗ ។ល។

***<u>អេកូឡូស៊ី៖</u>*** ជាវិទ្យាសាស្ត្រដែលសិក្សា ពីទំនាក់ទំនង រវាងភាវរស( សត្វ ឬ រុក្ខជាតិ) ជាមួយ និងមជ្ឈដ្ឋានជុំវិញ។ ឧទាហរណ៍៖ អេកូឡូស៊ីរុក្ខជាតិ គឺជាការសិក្សា ពីទំនាក់ទំនង រវាងរុក្ខជាតិជាមួយនឹងមជ្ឈដ្ឋានដែលវាលូតលាស់។

***ប្រព័ន្ធអេកូឡូស៊ីៈ*** គឺជាសំណុំសារពាង្គកាយមានជីវិត ទាំងអស់ (សត្វ រុក្ខជាតិ និង មីក្រូសារពាង្គកាយ) រួមជាមួយនិងមជ្ឈដ្ឋានមានជីវិត និងអន្តរកម្មរវាងមជ្ឈដ្ឋានមានជីវិត ទាំងនោះជាមួយមជ្ឈដ្ឋានដែលវារស់នៅ ក្នុងទីកន្លែងណាមួយកំណត់។ ឧទាហរណ៍ទី១ ៖ ប្រព័ន្ធអេកូឡូស៊ីទឹកសាប ដីគោក ប្រព័ន្ធអេកូឡូស៊ីសមុទ្រ។ល។



រូបភាពទី ១ ៖ ស្ថានប្រព័ន្ធបឹង www.gpb.org/.../aquatic-other-resources

ឧទាហរណ៍ទី២ ៖ ជាទូទៅភាវៈមានជីវិតតែងតែធ្វើចលនាផ្លាស់ទីពីស្ថានប្រព័ន្ធមួយទៅស្ថានប្រព័ន្ធមួយទៀត ដូចជាសត្វ ស្លាប (ចាប) ម្យ៉ាងតែងតែផ្លាស់ទីជម្រករស់នៅរបស់វា នៅសិសិររដូវក្នុងស្ថានប្រព័ន្ធរបស់វាទៅក្នុងស្ថានប្រព័ន្ធ ថ្មីមួយទៀត នៅរដូវក្តៅ។

ឧទាហរណ៍ទី៣ ៖ ស្ថានប្រព័ន្ធ បឹងទន្លេសាប គឺជានិមិត្តរូប ដ៏សំខាន់នៃអត្តសញ្ញាណជាតិរបស់ប្រទេសកម្ពុជាដែលគេចាត់ទុកជាបេះដូង និងដួងព្រលឹងរបស់ប្រទេស។ បឹងនេះ គឺជាបឹងដែលធំជាងគេនៅអាស៊ីអាគ្នេយ៍ និង មានផ្ទៃក្រឡា ២៥០០-៣០០០ គីឡូម៉ែត្រក្រឡា នៅរដូវប្រាំង និង កើនឡើងដល់ ១០៤០០ គីឡូម៉ែត្រ ក្រឡានៅរដូវវស្សា។ វាសម្បូរទៅដោយជីវចម្រុះច្រើនប្រភេទ (រុក្ខជាតិ ១១៥ ប្រភេទ ត្រី ២១៥ ប្រភេទ និងសត្វស្លាបជាង ២០០ ប្រភេទ ល្មូនជាច្រើនប្រភេទ និងមាន ប្រភេទសត្វ និងរុក្ខជាតិជាច្រើនទៀត ។

## ១.២ ប្រភេទធនធានធម្មជាតិ

ជាទូទៅធនធានធម្មជាតិ ត្រូវបានគេបែងចែកជាពីរប្រភេទ គឺធនធានធម្មជាតិកើតឡើងវិញ (ធនធានកើតឡើងក្នុងរយៈពេលខ្លី) និងធនធានមិនកើតឡើងវិញឬធនធានកើតឡើងវិញក្នុងរយៈពេលដ៏យូរ។

### ១.២.១ ធនធានធម្មជាតិកើតឡើងវិញ

គឺជាធនធានដែលអាចកើតឡើងវិញបានដោយខ្លួនឯងឬ ដោយអំពើរបស់មនុស្ស ក្នុងរយៈពេលខ្លី ឬមានប្រភពមិនចេះអស់ ព្រោះធនធានប្រភេទនេះនឹងកើតឡើងវិញម្តងទៀតដូចជា ព្រៃឈើ សត្វព្រៃ ត្រី ទឹក ដី ថាមពលព្រះអាទិត្យ និងថាមពលខ្យល់ជាដើម។



រូបភាពទី២ ៖ ធនធានធម្មជាតិកើតឡើងវិញ (ប្រភព៖ វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល)

ឧទាហរណ៍ រុក្ខជាតិ គឺជាធនធានធម្មជាតិកើតឡើងវិញ ព្រោះវាអាចដុះលូតលាស់ ឬធ្វើការដាំដុះឡើងវិញ។ ធនធានធម្មជាតិមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ជីវិត។ តែទោះជាមានធនធានធម្មជាតិកើតឡើងវិញ ដ៏សម្បូរបែបយ៉ាងណាក៏ដោយក៏យើងត្រូវថែរក្សាការ ពារធនធានទាំងនេះដោយប្រុងប្រយ័ត្ន ព្រោះវាអាចទទួលរង ការបំផ្លាញដោយងាយ។

ការគ្រប់គ្រងដោយមានយកចិត្តទុកដាក់ខ្ពស់ និងឆ្លាតវៃ អាចធ្វើឲ្យធនធានទាំងនោះកើតឡើងវិញជារៀងរហូត។ ការប្រើប្រាស់ធនធានធម្មជាតិកើតឡើងវិញ ដោយនិរន្តរភាពអាចធ្វើឡើងបានលុះត្រាតែល្បឿននៃការប្រើប្រាស់វាតូចជាងល្បឿននៃការកើតឡើងវិញរបស់វា។

### ១.២.២ ធនធានមិនកើតឡើងវិញ

គឺជាធនធានដែលអាចប្រើទៅអស់ទាំងស្រុង ឬ មាននៅក្នុងលក្ខខណ្ឌកំណត់ណាមួយ ឬក៏ជាធនធានដែលចំណាយពេលវេលាដ៏យូរនៃធរណីកាល (រាប់លានឆ្នាំ) ដើម្បីកកើតឡើងវិញ។ ធនធានទាំងនោះរួមមានប្រេងកាត ធ្យូងថ្ម ឧស្ម័នធម្មជាតិមួយចំនួន រ៉ែដែក រ៉ែមាស រ៉ែត្បូង និង រ៉ែផ្សេងៗទៀត។ នៅពេលបច្ចុប្បន្ននេះ ធនធានមិនកើតឡើងវិញមួយចំនួនកាន់តែខ្សត់ទៅៗ ដោយសារការទាញយកធនធានទាំងនោះមកប្រើប្រាស់ដើម្បីបម្រើដល់សេដ្ឋកិច្ច។ ធនធានធម្មជាតិ ភាគច្រើន

ជាធនធានធម្មជាតិមិនកើតឡើងវិញ ទោះបីជាវាអាចកើតឡើងវិញក៏ដោយក៏ធនធានទាំង នោះត្រូវការរយៈពេលយូរដើម្បីក៏កើតឡើងវិញដែរ ហើយយើងនឹងមិនមានឱកាសប្រើប្រាស់វាម្តង ទៀតឡើយ។




**រូបភាពទី ៣ ៖ ធនធានធម្មជាតិមិនកើតឡើងវិញ(រូបភាពដកស្រង់ចេញពី www.google.com)**

ឧទាហរណ៍ ៖ ផែនដីត្រូវការពេលវេលា ១០០០០០ ឆ្នាំ ដើម្បីបង្កើត ប្រេងឥន្ធនៈ ធ្យូងថ្ម និង ឧស្ម័នធម្មជាតិ ដែលមនុស្សប្រើប្រាស់ក្នុងរយៈពេលតែមួយឆ្នាំ។

ការប្រើប្រាស់ធនធានធម្មជាតិមិនកើតឡើងវិញប្រកបដោយនិរន្តរភាព គឺត្រូវផ្អែកលើការកែច្នៃឡើងវិញ និងការរកប្រភពធនធានថ្មី ដើម្បីជំនួសធនធានទាំងនោះដូចជាថាមពលព្រះអាទិត្យសម្រាប់ផលិតផលអគ្គិសនី។

**ធនធានធម្មជាតិ**

| **ធនធានធម្មជាតិកើតឡើងវិញ** | **ធនធានធម្មជាតិមិនកើតឡើងវិញ** |
|---|---|
| គឺជាធនធានដែលកើតឡើងវិញបានដោយធម្មជាតិ ឬធនធានមានប្រភពមិនចេះអស់។<br>- ថាមពលខ្យល់<br>- ថាមពលកម្តៅ ពន្លឺព្រះអាទិត្យ<br>- ដី<br>- ទឹកលើដី និង ក្រោមដី<br>- ព្រៃឈើ សត្វព្រៃ ត្រី<br>- វត្ថុមានជីវិតរួមទាំងមនុស្សផងដែរ។ | គឺសន្មត់ទៅលើធនធានដែលចំណាយពេលវេលាដ៏យូរដើម្បីកកើតឡើងវិញ។ គឺជាធនធានដែលអាចប្រើប្រាស់អស់ឬមាននៅក្នុងលក្ខខណ្ឌកំណត់ណាមួយ។<br>- ផូស៊ីលឥន្ធនៈ(ឧស្ម័នធម្មជាតិ ធ្យូងថ្ម និងប្រេងឆៅ)<br>- រ៉ែមាស រ៉ែត្បូង .... |

**រូបភាពទី ៤ ៖ គំនូសតាងប្រភេទធនធានធម្មជាតិ**

ទាក់ទងនឹងប្រធានបទធនធានធម្មជាតិនេះ យើងគួរពិចារណាថា ប្រភេទសត្វ និងរុក្ខជាតិមួយចំនួនដែលជាធនធានធម្មជាតិកើតឡើងវិញ និងអាចក្លាយទៅជាធនធានធម្មជាតិមិនកើតឡើងវិញដែរ។ ប្រសិនប្រភេទទាំងនោះត្រូវបានបំផ្លាញអស់វា នឹងក្លាយ ទៅជាប្រភេទដែលវិនាសផុតពូជពីផែនដីរបស់យើងនេះ។ ឧទហរណ៍ គោព្រៃ ជាសត្វដែលតំណាងឲ្យអត្តសញ្ញាណនៃប្រទេសកម្ពុជាដែលធ្លាប់តែមាននៅទសវត្សរ៍ឆ្នាំ ១៩៦០ ប្រហែលជាវិនាសផុតពូជពីប្រទេសកម្ពុជាបាត់ទៅហើយ។ ចំណែកឯត្រីរាជ ត្រីគល់រាំង និងសត្វផ្សោត ដែលបច្ចុប្បន្ននៅសល់តិចតួចប៉ុណ្ណោះនៅប្រទេសកម្ពុជាវានឹងអាចក្លាយទៅជាធនធានមិនកើតឡើងវិញ ប្រសិនប្រើវិនាសផុតពូជពីប្រទេសកម្ពុជា។ លើសពីនេះទៅទៀត មានការពិភាក្សាអំពីប្រភេទថាមពលដែលកើតឡើងវិញ និងថាមពលមិនកើតឡើងវិញ ដោយមនុស្សគ្រប់រូបយល់ឃើញថា ថាមពលពីប្រេងឥន្ធនៈ ធ្យូងថ្ម និងឧស្ម័ន ធម្មជាតិជាធនធានដែលមិនអាចកើតឡើងវិញ ព្រោះថាបើយើងជុតប្រេងឥន្ធនៈ ដើម្បីទាញយកថាមពលមកប្រើប្រាស់ប្រេងឥន្ធនៈនោះនឹងបាត់បង់ជារៀងរហូត ហើយមានផលប៉ះពាល់ដល់បរិស្ថានយ៉ាងខ្លាំង។ ដូចនេះការទាញយកថាមពលផ្សេងៗទៀតដូចជា ថាមពលខ្យល់ ថាមពលកម្តៅ ថាមពលទឹក ជីវម៉ាស អាចជាជម្រើសដ៏ប្រសើរក្នុងពេលបច្ចុប្បន្ន។

## ១.៣ ប្រព័ន្ធនៃធនធានធម្មជាតិ

គេអាចចែកធនធានធម្មជាតិជាបីប្រព័ន្ធ៖

***ប្រព័ន្ធទឹក៖*** រួមមានស្ទឹង បឹង តំបន់ដីសើម ទឹកមានចរន្តហូរ ទឹកក្រោមដី និងមាត់ច្រាំង ។

***ប្រព័ន្ធដី៖*** រួមមានដីថ្ម និងរុក្ខជាតិ ព្រមទាំងប្រព័ន្ធដី ខាងក្រោម និងលក្ខណៈសណ្ឋានដី ។

***ប្រព័ន្ធខ្យល់៖*** បរិយាកាស កម្តៅ និងថាមពលខ្យល់ ។ **ឧទាហរណ៍៖** ការកើនឡើងកម្តៅនៃផែនដី ខ្យល់បក់ ខ្យល់បរិសុទ្ធ ។




**រូបភាពទី ៥ ៖ ប្រព័ន្ធនៃធនធានធម្មជាតិ (រូបភាពយកចេញពី** www.google**)**

ការដកហូតដើមឈើទាំងនេះ ក៏អាចប៉ះពាល់ដល់ គុណភាពខ្យល់ សីតុណ្ហភាព និង អាកាសធាតុផងដែរព្រោះថាដើមឈើ ផ្តល់អុកស៊ីសែន និង ធ្វើឲ្យមាន លំនឹងសីតុណ្ហភាពនិងខ្យល់ក្នុងបរិយាកាស។

ភាពសាំញ៉ាំនៃអន្តរកម្ម (ទំនាក់ទំនង) នេះជាមូលហេតុបញ្ជាក់យ៉ាងច្បាស់ថាការគ្រប់គ្រងធនធានធម្មជាតិមានប្រសិទ្ធភាព ត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើផលប៉ះពាល់ផ្សេងៗដែលបណ្តាលមកពីសកម្មភាពទាញយកធនធានមកប្រើប្រាស់។

## ១.៤ តម្លៃធនធានធម្មជាតិ

នៅក្នុងបរិបទនៃការគ្រប់គ្រងធនធានធម្មជាតិ តម្លៃធនធានធម្មជាតិចែកជាបីៈ តម្លៃប្រើ ប្រាស់ តម្លៃជម្រើស និង តម្លៃមិនប្រើប្រាស់ (តម្លៃអភិរក្ស)។

### ១.៤.១ តម្លៃប្រើប្រាស់

តម្លៃប្រើប្រាស់បង្ហាញពីការប្រើប្រាស់ធនធានធម្មជាតិដោយផ្ទាល់លើធនធានបរិស្ថាន ដើម្បីបំពេញតម្រូវការប្រចាំថ្ងៃ។ ឧទាហរណ៍ ៖ ត្រីដែលបានចាប់ពីសមុទ្រឬ ទន្លេ ដើមឈើដកហូតចេញមកពីព្រៃឈើ ទឹកដែលដកចេញពីទន្លេ ស្ទឹង សម្រាប់ធារាសាស្ត្រ សោភណ្ឌភាពផ្តល់ដោយធម្មជាតិ។ ឧទាហរណ៍៖ ត្រីដែលបានដកហូត ចេញពីសមុទ្រ ឬទន្លេដើមឈើដកហូតចេញពីព្រៃឈើ ទឹកដែលដកចេញពីទន្លេ ស្ទឹងសម្រាប់ធារាសាស្ត្រ សោភណ្ឌភាពផ្តល់ដោយធម្មជាតិ។ តម្លៃប្រើប្រាស់បែងចែកជា **តម្លៃប្រើប្រាស់ផ្ទាល់ និងតម្លៃប្រើប្រាស់ប្រយោល។**

- ***<u>តម្លៃប្រើប្រាស់ផ្ទាល់៖</u>*** សំដៅលើតម្លៃទទួលបានពីផលិតផលដែលផ្តល់ឲ្យដោយធនធានធម្មជាតិ។ ផលិតផលគឺជាអ្វី គឺជាអ្វីដែលយើងអាចប៉ះបាន មើលឃើញហើយអាចស្តុកបាន និងដឹកជញ្ជូនបាន។ ផលិតផលដែលផ្តល់ដោយធម្មជាតិមានដូចជាៈ ឈើហ៊ុប ត្រី សាច់ បន្លែផ្លែឈើនិងផលិតផលផ្សេងៗជាច្រើនទៀត។

  ឧទាហរណ៍៖ តម្លៃប្រើប្រាស់រួមមានសកម្មភាពនៃការប្រើប្រាស់ធនធានធម្មជាតិតាមរយៈការនេសាទត្រីពីបឹងទន្លេសាបការប្រមូលឈើហ៊ុប និងអនុផលព្រៃឈើ ការទាញយកទឹកពីបឹងទន្លេសាប ការប្រមូលឈើហ៊ុប និងអនុផល ព្រៃឈើការទាញយកទឹកពីបឹងទន្លេសាបសម្រាប់ស្រោចស្រពដើម។ តម្លៃប្រើប្រាស់ត្រូវបានបាត់បង់ប្រសិនវាត្រូវ រងការបំពុល និងការបំផ្លាញ ។



**រូបភាពទី ៦ ៖ តម្លៃប្រើប្រាស់ផ្ទាល់នៃធនធានធម្មជាតិ (ប្រភព លោក គឹម សារិន ក្រសួងបរិស្ថាន)**

- ***តម្លៃប្រើប្រាស់ប្រយោល ឬគាំពារ៖*** សំដៅលើសេវាកម្មដែលផ្ដល់ឲ្យដោយធនធានធម្មជាតិ ហើយតម្លៃនេះមានសារៈសំខាន់ណាស់សម្រាប់រក្សា លំនឹងបរិស្ថានដែលជួយទ្រទ្រង់ដោយប្រយោលដល់សកម្មភាពសេដ្ឋកិច្ច និងសុខមាលភាពរបស់មនុស្ស។ សេវាកម្មសំដៅទៅលើធនធានអរូបី ឬអ្វីដែលមើលពុំឃើញមិនអាចផ្ទុក និងដឹកជញ្ជូនបាន។ សេវាកម្មដែលផ្ដល់ដោយធនធានធម្មជាតិមានដូចជាៈ រក្សាលំនឹងបរិស្ថាន អាងកាត់បន្ថយការបំពុល គ្រប់គ្រងទឹកជំនន់រក្សាលំនឹងសីតុណ្ហភាព និងរក្សាទីជម្រាល តម្លៃសោភណ្ឌភាព តម្លៃកំសាន្ត តម្លៃវប្បធម៌ ទីជម្រកសម្រាប់សត្វ និងរុក្ខជាតិ។ ឧទាហរណ៍៖ ព្រៃឈើជួយជារបាំងការពារខ្យល់ព្យុះ ដែលការពារលំនៅដ្ឋាន ជីវិត មនុស្ស និងសត្វ។




**រូបភាពទី ៧ ៖ តម្លៃប្រើប្រាស់ប្រយោល ឬសេវាកម្មផ្ដល់ដោយធម្មជាតិ**

មនុស្ស និងធម្មជាតិមានទំនាក់ទំនងគ្នាយ៉ាងជិតស្និត ហើយមនុស្សជាផ្នែកមួយនៃបរិស្ថាន។ មនុស្សបានធ្វើការអភិវឌ្ឍសង្គម និងបច្ចេកវិទ្យាទំនើបបាន ក៏អាស្រ័យលើការទាញផលប្រយោជន៍ធម្មជាតិដែរ។ ការណាមនុស្សធ្វើឲ្យខូចដល់ប្រព័ន្ធអេកូឡូស៊ីដែលជាប្រព័ន្ធអន្តរកម្មរវាងភាវៈមានជីវិតដូចជារុក្ខជាតិ សត្វ និងមីក្រុប និងផ្នែកផ្សេងៗនៃបរិស្ថាននោះ មនុស្ស និងទទួលរងនូវផលប៉ះពាល់ពីវាមកវិញចៀសមិនផុតឡើយ។

ឧទាហរណ៍៖ ការប្រែប្រួលអាកាសធាតុបណ្ដាលមកពីការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (ឧស្ម័នកាបូនិច ស៊ុលផួរ មេតាន ក្លរភ្លុយអរ៉ូកាបូន...) ច្រើនពីរោងចក្រឧស្សាហកម្មរថយន្ត កន្លែងចិញ្ចឹមសត្វ និងសកម្មភាពផ្សេងៗទៀតរបស់មនុស្សនៅក្នុងបរិយាកាស។ ជាលទ្ធផល មនុស្សបានទទួលនូវគ្រោះធម្មជាតិវិញដូចជាគ្រោះរាំងស្ងួត ភ្លៀងមិនទៀងទាត់ ទឹកជំនន់ បរិយាកាសក្ដៅជាងមុន និងការ

កើនឡើងកម្ពស់ទឹកសមុទ្រជាដើម។ ដូចនេះយើងត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការថែរក្សា និង ប្រើប្រាស់ធនធានធម្មជាតិឲ្យបានសមស្រប និងមាននិរន្តរភាពសម្រាប់ប្រយោជន៍មនុស្សបច្ចុប្បន្ន និង ជំនាន់ក្រោយ ។

**តារាងទី ១ ៖ ផលិតផល និងសេវាកម្មផ្តល់ឲ្យដោយធនធានធម្មជាតិ**

| **ធនធានធម្មជាតិ** | **មុខងារផ្តល់ផលិតផល និងសេវាកម្ម** | |
|---|---|---|
| ***ព្រៃឈើ*** | មុខងារ | ផលិតកម្ម |
| | ផលិតផល | សសរផ្ទះ អុសដុត អាហារ (ផ្លែឈើ ផ្សិត។ល។) អាហារសត្វទឹកបរិភោគ និងធនធានសេនេទិច |
| | មុខងារ | រក្សាលំនឹងផ្តល់ទីជម្រក និងព័ត៌មាន |
| | សេវាកម្ម | រក្សាគុណភាពខ្យល់ ទីជម្រាល ចម្រោះទឹក រក្សាលំនឹងអាកាសធាតុ អាងស្តុកឧស្ម័នកាបូនិច របាំងខ្យល់ជម្រកសត្វ និងរុក្ខជាតិ ការកម្សាន្ត និងតម្លៃជំនឿ ។ |
| ***ដី*** | មុខងារ | ផលិតកម្ម |
| | ផលិតផល | ដីផ្នែកខាងលើ និងគម្របដី |
| | មុខងារ | រក្សាលំនឹង ទីជម្រក |
| | សេវាកម្ម | អាងស្តុកការបំពុល បំបែកសារធាតុសរីរាង្គ ជម្រកសម្រាប់សត្វ រុក្ខជាតិ និងមីក្រូសារពាង្គកាយ |
| ***បរិយាកាស*** | មុខងារ | ផលិតកម្ម |
| | ផលិតផល | អុកស៊ីសែន |
| | មុខងារ | រក្សាលំនឹង |
| | សេវាកម្ម | ការពារកាំរស្មីស្វាយអ៊ុលត្រា UV រក្សាលំនឹងសីតុណ្ហភាព រក្សាគុណភាពខ្យល់ |
| ***ទឹក*** | មុខងារ | ផលិតកម្ម |
| | ផលិតផល | ទឹកបរិភោគ ទឹកស្រោចស្រព |
| | មុខងារ | រក្សាលំនឹង ទីជម្រក |
| | សេវាកម្ម | រក្សាលំនឹងអាកាសធាតុ និងសីតុណ្ហភាព អាងស្តុកសំណល់រាវ ទីជម្រកសម្រាប់សត្វ និងរុក្ខជាតិ និងមីក្រូសារពាង្គកាយ |

**ដកស្រង់ចេញពី៖ MRC.GTZ, 2005 in Natural Resource and Governance: Incentive for Sustainable Resource Use in the Mekong River Basin. (Original source: own presentation of MRC/GTZ based on de Groot, Wilson & Boumans 2002; World Resource Institute 2000)**

### ១.៤.២ តម្លៃជម្រើស

តម្លៃជម្រើស ឆ្លុះបញ្ចាំងពីតម្លៃដែលមនុស្សឲ្យតម្លៃទៅលើលទ្ធភាពនាពេលអនាគតនៃការប្រើប្រាស់ធនធានបរិស្ថាន។ ដូចនេះតម្លៃជម្រើស គឺឆ្លុះបញ្ចាំងពីឆន្ទៈដើម្បីរក្សាជម្រើសក្នុងការប្រើប្រាស់ធនធានបរិស្ថាននៅពេលអនាគត ទោះបីជាអ្នកណាម្នាក់មិនបានប្រើប្រាស់វានៅពេលបច្ចុប្បន្នក៏ដោយ។

ឧទាហរណ៍៖ នៅក្នុងសហគមន៍នេសាទ ឬសហគមន៍ព្រៃឈើ គណៈកម្មការសហគមន៍ និងប្រជាពលរដ្ឋបានរួមគ្នាកំណត់តំបន់ប្រើប្រាស់នៅក្នុងភូមិ ឃុំរបស់ខ្លួន ដោយកំណត់ឲ្យមានតំបន់ប្រើប្រាស់ឆ្នាំទី១ ទី២ ឆ្នាំទី៣ និងឆ្នាំបន្តទៀត (អាស្រ័យទៅលើការកំណត់វដ្តនៃការដកហូត) និងដើម្បីដកហូតប្រើប្រាស់ធនធាននៅក្នុងតំបន់ប្រកបដោយនិរន្តរភាព។

### ១.៤.៣ តម្លៃអភិរក្ស

តម្លៃអភិរក្ស គឺឆ្លុះបញ្ចាំងពីការសង្កេតជារួមដែលមនុស្សជាច្រើនមានចំណាប់អារម្មណ៍ក្នុងការចំណាយដើម្បីធ្វើឲ្យប្រសើរឡើង និងការការពារធនធានដែលមនុស្សទាំងនោះមិនដែលបានប្រើ (Tietenberg, T.2003) ។ តម្លៃនេះបង្ហាញពីទស្សនៈរួមមួយដែលប្រជាជនមានឆន្ទៈចូលរួមការពារ និងអភិរក្សធនធានដែលពួកគេ នឹងមិនប្រើប្រាស់។ ឧទាហរណ៍៖ នៅក្នុងតំបន់ការពារធម្មជាតិនីមួយៗ គេតែងតែមានការកំណត់តំបន់អភិរក្ស ដែលតម្រូវឲ្យមានការការពារយ៉ាងតឹងរឹងដើម្បីរក្សាទុកប្រភេទសត្វ និងរុក្ខជាតិ និងធ្វើឲ្យប្រភេទទាំងនោះកកើតឡើងវិញ ។

**តារាងទី ២ ៖ ឧទហណ៍នៃតម្លៃធនធានព្រៃឈើ**

| តម្លៃប្រើប្រាស់ | | តម្លៃជម្រើស | តម្លៃមិនប្រើប្រាស់ (តម្លៃអភិរក្ស) |
|---|---|---|---|
| **តម្លៃប្រើប្រាស់ផ្ទាល់** | **តម្លៃប្រើប្រាស់ប្រយោល (តម្លៃថែរក្សាលំនឹងបរិស្ថាន)** | | |
| ប្រើប្រាស់ឈើហ៊ុបដោយនិរន្តរភាព | ការពារទីជម្រាល | បង្ហាញពីការប្រើប្រាស់ធនធាននាពេលអនាគត | កេរ្តិ៍តំណែលវប្បធម៌ |
| ប្រើប្រាស់អនុផលព្រៃឈើ | វដ្តសារធាតុចិញ្ចឹម | | ជីវចម្រុះ |
| ដំណើរកម្សាន្តទេសចរណ៍ | កាត់បន្ថយការបំពុលខ្យល់ | | |
| ប្រើប្រស់ធ្វើជាឱសថ | មុខងាររក្សាលំនឹងអាកាសធាតុ | | |
| សេនេទិចរុក្ខជាតិ | ផ្ទុកកាបូន | | |
| ការអប់រំនិងស្រាវជ្រាវ | ជីវចម្រុះ | | |
| ជម្រកមនុស្ស | | | |

**ប្រភព៖** O'Brien, N. (1999): Environment: Concepts and Issue - A focus on Cambodia

# ផ្នែកទី ២ ៖ ការគ្រប់គ្រងធនធានធម្មជាតិ

## ២.១ សាវតានៃការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងប្រទេសកម្ពុជា

ការគ្រប់គ្រងធនធានធម្មជាតិ គឺមានចាប់តាំងពីយូរយាណាស់មកហើយដោយកាលពីដើមឡើយមនុស្សសម័យនោះតែងតែប្រើចំណេះដឹងមូលដ្ឋានរបស់ខ្លួន ដូចជាជនជាតិដើមភាគតិចតាមលក្ខណៈប្រពៃណីរបស់ខ្លួនក្នុងការប្រើប្រាស់ និងការគ្រប់គ្រងធនធានធម្មជាតិ។ ក៏ប៉ុន្តែចំណេះបានបាត់ទៅវិញដោយសារតែការគ្រប់គ្រងធនធានធម្មជាតិតាមបែបមជ្ឈការ និងការគ្រប់គ្រងតាមបែបបច្ចេកទេសនៅក្នុងកំឡុងពេលនៃការគ្រប់គ្រងដោយអនានិគមបារាំង។

ជាក់ស្តែងការគ្រប់គ្រងព្រៃឈើមានច្រើនប្រភេទដូចជា ការគ្រប់គ្រងតាមបែបមជ្ឈការមាននៅក្នុងសម័យអានានិគមនិយមបារាំង និងបន្តចូលទៅក្នុងសម័យសង្គមរាស្ត្រ និយម។ ឆ្នាំ ១៩៨០ ក្រុមសាមគ្គីត្រូវបានបង្កើតឡើងដែលមានសិទ្ធិប្រមូលផលឈើហ៊ុបដើម្បីលក់ឲ្យនាយកដ្ឋានរុក្ខាប្រមាញ់។ គួរកត់សម្គាល់ថា ការធ្វើអាជីវកម្ម ព្រៃឈើមានការកើនឡើងនៅឆ្នាំ ១៩៩០ ដែលធ្វើឲ្យមានការកាប់ព្រៃឈើកាន់តែកើនឡើង។ នៅឆ្នាំ ១៩៩៤ កម្ពុជាបានអនុវត្តការគ្រប់គ្រងព្រៃឈើតាមប្រព័ន្ធព្រៃសម្បទាន និងអាជ្ញាប័ណ្ណប្រមូលផលទៅឲ្យក្រុមហ៊ុនឯកជនដើម្បីធ្វើអាជីវកម្មនិង គ្រប់គ្រង។ នៅឆ្នាំ១៩៩៩រដ្ឋាភិបាលកម្ពុជាបានលុបចោលព្រៃសម្បទាន វិញប៉ុន្តែការរិះគន់នៅតែ កើតមាន និងធ្វើឲ្យមានជម្លោះរវាងក្រុមហ៊ុនឯកជន ជាមួយសហគមន៍មូលដ្ឋាន។ ស្របពេលជាមួយគ្នានេះដែរ ការអភិវឌ្ឍន៍សហគមន៍ព្រៃឈើក៏មានការកើនឡើងដែលជាការគ្រប់គ្រងតាមវិមជ្ឈការ។

ចំណែកឯការគ្រប់គ្រងជលផលវិញ ការគ្រប់គ្រងមានលក្ខណៈស្មុកស្មាញដោយមានទាំងផ្លូវការ និងមិនផ្លូវការ។ នៅកំឡុងឆ្នាំ ១៨៥៩-១៨៩៧ ក្នុងរបបគ្រប់គ្រងរជ្ជកាលព្រះបាទនរោត្តម តំបន់ជលផលត្រូវបានលក់ ឬផ្តល់សម្បទានឲ្យអ្នកធ្វើជំនួញដើម្បីធ្វើអាជីវកម្មទៅលើតំបន់ទាំងនោះ។ នៅក្នុងសម័យអនានិគមនិយមបារាំងប្រទេសកម្ពុជាបានបន្តប្រព័ន្ធដូចនេះដដែល ហើយនៅក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិ ឆ្នាំ ១៩០៨ ច្បាប់ជលផលដំបូងត្រូវបានបង្កើតឡើង។ បន្ទាប់មកប្រព័ន្ធនេះនៅបន្តរហូតមកដល់សម័យ ប៉ុល ពត បន្តទៀតនៅក្នុងឆ្នាំ ១៩៧៥។

បន្ទាប់ពីរបប ប៉ុល ពត ដួលរលំ ឆ្នាំ ១៩៧៩ ប្រព័ន្ធនេសាទសហករត្រូវបានបង្កើតឡើងដែលមានក្រុមសាមគ្គីគ្រប់គ្រង ទៅលើធនធានជលផល។ នៅក្នុងដើមទស្សវត្សរ៍ ១៩៨០ ប្រព័ន្ធសម្បទានឡូត៍នេសាទ ដែលធ្លាប់មានពីមុនសម័យ ប៉ុល ពត ត្រូវបានយកមកប្រើឡើងវិញដោយរដ្ឋាភិបាលដើម្បីរកប្រាក់ចំណូលជាតិ ហើយប្រព័ន្ធនេះនៅតែមានដល់ពេលបច្ចុប្បន្ននេះ។ ចាប់តាំងពី ឆ្នាំ ១៩៩៨ ប្រពន្ធ័ដេញថ្លៃលើសម្បទានឡូត៍នេសាទត្រូវបានអនុវត្តដោយអ្នកដេញថ្លៃ។ ប្រព័ន្ធ បែបនេះតែងតែមានជម្លោះរវាងម្ចាស់ឡូត៍ និងអ្នកនេសាទ ជាពិសេសតំបន់ដែលអាចធ្វើនេសាទដោយអ្នកនេសាទខ្នាតតូច។ ហេតុដូចនេះហើយ នៅឆ្នាំ ២០០០ នាយករដ្ឋមន្ត្រីបានបញ្ជាឲ្យមានការកែ

ទម្រង់ប្រព័ន្ធគ្រប់គ្រងវិស័យជលផលសំដៅទៅដល់ការកាត់បន្ថយតំបន់ឡូត៍នេសាទ ជាង ៥៦.២៣% ហើយឈានមកដល់ឆ្នាំ ២០១២ នេះ ឡូត៍នេសាទត្រូវបានលុបចោលទាំងស្រុងសម្រាប់ការប្រើប្រាស់ជាលក្ខណៈគ្រួសារ និងអភិរក្សទូទាំងប្រទេស។ ហើយបន្ទាប់មកសហគមន៍នេសាទក៏ត្រូវបានបង្កើតឡើងជាហូហែរ និងមានការរីកចម្រើន ដែលការគ្រប់គ្រងគ្រងនេះហៅថាការគ្រប់គ្រងតាមបែបវិមជ្ឈការដែលមានការចូលរួមពីសហគមន៍មូលដ្ឋាន ហើយក្នុងនោះផងដែរព្រះរាជក្រឹត្យ និងអនុក្រឹត្យសហគមន៍នេសាទបានបង្កើតឡើងនៅឆ្នាំ ២០០៥ ហើយ បន្ទាប់មកទៀតរាជរដ្ឋាភិបាលមានការគាំទ្រគោលនយោបាយ និងច្បាប់ផ្សេងៗទៀតលើវិស័យនេះក៏ប៉ុន្តែការអនុវត្តតាមបែបមជ្ឈការនេះទាមទារឲ្យមានការគាំទ្រពីសំណាក់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា។ ស្រដៀងគ្នានេះដែរការគ្រប់គ្រងដីធ្លី និងធនធានរ៉ែក៏មានការកែទម្រង់លើការគ្រប់គ្រងផងដែរ ។

## ២.២ និយមន័យនៃការគ្រប់គ្រងធនធានធម្មជាតិ

មាននិយមន័យផ្សេងៗជាច្រើនទៅលើការគ្រប់គ្រងធនធានធម្មជាតិ។ ខាងក្រោមនេះជានិយមន័យពីរ អំពីការគ្រប់គ្រងធនធានធម្មជាតិ៖

- តាមវចនានុក្រមបរិស្ថាន និង អភិរក្សរបស់សាកលវិទ្យាល័យ អុកហ្វត (Oxford) ឆ្នាំ ២០០៨ បានកំណត់និយមន័យការគ្រប់គ្រងធនធានធម្មជាតិថា "ជាការគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកទៅលើមូលដ្ឋាននិរន្តរភាព ដែលជាទូទៅមានមធ្យោបាយផ្សេងៗដែលអាចបំពេញគោលបំណងជាច្រើនដោយរួមមានការអភិរក្សសត្វព្រៃ និងស្ថានប្រព័ន្ធ ព្រមទាំងកាត់បន្ថយផលប៉ះពាលបរិស្ថាន និងការផ្លាស់ប្តូរបរិស្ថាន"។
- ដោយផ្អែកលើបទពិសោធន៍ក្នុងការអនុវត្តការគ្រប់គ្រងធនធានធម្មជាតិ ការគ្រប់គ្រងធនធានធម្មជាតិគឺសំដៅទៅលើសកម្មភាពនានាដើម្បីគ្រប់គ្រងការពារ អភិវឌ្ឍ អភិរក្ស និង ស្តារឡើងវិញធនធានធម្មជាតិ (វិទ្យាស្ថាន CBNRM LI, 2005)។ ការគ្រប់គ្រងធនធានធម្មជាតិនេះគឺជាសកម្មភាពដើម្បីឆ្លើយតបទៅនិងគោលនយោបាយ និងយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាលដោយមានការចូលរួមពីគ្រប់បណ្តាអ្នកពាក់ពន្ធ័។ ម្យ៉ាងទៀតគេអាចនិយាយបានថាការគ្រប់គ្រងធនធានធម្មជាតិ គឺសំដៅទៅលើការគ្រប់គ្រង ដូចជា ការគ្រប់គ្រងដី ទឹក ព្រៃ ឈើ សត្វព្រៃ សត្វព្រៃ ដោយផ្តោតសំខាន់ទៅលើប្រសិទ្ធភាពនៃការគ្រប់គ្រងដែលផ្តល់គុណភាពនៃជីវិតទាំងមនុស្សបច្ចុប្បន្ន និង មនុស្សជំនាន់ក្រោយ។

## ២.៣ ការគ្រប់គ្រងធនធានធម្មជាតប្រកបដោយនិរន្តរភាព

### ២.៣.១ និយមន័យ

ការគ្រប់គ្រងធនធានប្រកបដោយនិរន្តរភាពគឺជាការគ្រប់គ្រងដែលបំពេញនូវសេចក្តីត្រូវការរស់មនុស្សបច្ចុប្បន្ន ដោយពុំធ្វើឲ្យខូចខាតដល់លទ្ធភាពរបស់មនុស្សជំនាន់ក្រោយឡើយ។

ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាពត្រូវបានពិពណ៌នាថា ជាការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិដើម្បីផ្តល់អាហារ ថាមពល និងវត្ថុធាតុដើមដល់មនុស្សទាំងអស់ ដោយមិនបន្សល់ទុកការខូចខាតបរិស្ថាន និង ផលប្រយោជន៍សម្រាប់មនុស្សជំនាន់ក្រោយឡើយ។

## ២.៤.២ ចំណុចគួរពិចារណាអំពីការគ្រប់គ្រងធនធានធម្មជាតិ

ផ្នែកសំខាន់ៗ ចំនួនបីដែលយើងត្រូវពិចារណា ដើម្បីឈានទៅដល់ការគ្រប់គ្រងធនធានធម្មជាតិមាននិរន្តរភាព គឺ ផ្នែក សេដ្ឋកិច្ច សង្គម និង បរិស្ថាន។

- ***ផ្នែកបរិស្ថាន៖*** ធនធានធម្មជាតិ និងជីចម្រុះត្រូវបានថែរក្សា និង ការពារ (ដោយត្រួតពិនិត្យការបំពុល ការគ្រប់គ្រងសំណល់ និងលំហាបៃតង)។
  ក្នុងផ្នែកនេះធនធានធម្មជាតិត្រូវបានផ្តល់តម្លៃការពារលំនឹងបរិស្ថានដូចជាទប់ស្កាត់ខ្យល់ព្យុះ ទឹកជំនន់ធ្វើឲ្យមានខ្យល់អាកាសបរិសុទ្ធជាដើម ។
- ***ផ្នែកសង្គម៖*** ធានាឲ្យមានមានការប្រើប្រាស់ ការចូលរួម ការពិគ្រោះយោបល់ ការចែករំលែកព័ត៌មាននិងការបែងចែកផលប្រយោជន៍ប្រកបដោយសមភាព និងសមធម៌ក្នុងសហគមន៍ ដូចជាការទទួលបានសេវាសង្គម ទីលំនៅ និង សុវត្ថិភាពសារធារណៈជាដើម។ ធនធានធម្មជាតិផ្តល់ឲ្យតម្លៃខាងផ្នែកសង្គមដូចជា តម្លៃប្រពៃណី វប្បធម៌ ជំនឿ។ ឧទាហរណ៍ ព្រៃអារក្ស ទីកន្លែងគោរពបូជា......។
- ***ផ្នែកសេដ្ឋកិច្ច៖*** បង្កើនឲ្យមានផលប្រយោជន៍កាន់តែច្រើនពីធនធានធម្មជាតិនិងបន្ថយផលប៉ះពាល់ជាអវិជ្ជមានរបស់វាចំពោះបរិស្ថាន (ការដឹកជញ្ជូនការដោះដូរពានិជ្ជកម្មការទទួលបានការងារធ្វើ និងទេសចរណ៍)។ ធនធានធម្មជាតិជួយគាំទ្រដល់ផ្នែកសេដ្ឋកិច្ចតាមរយៈការទាញយកធនធានធម្មជាតិមកប្រើប្រាស់ និង ធ្វើពានិជ្ជកម្មដើម្បីទ្រទ្រង់ដល់សេដ្ឋកិច្ចជាតិ។



តាមរយៈរូបភាពខាងលើនេះគេអាចធ្វើការពន្យល់ដូចតទៅៈ

❖ ***ចំណុចប្រសព្វរវាងសង្គម និងបរិស្ថានៈ*** មានន័យថាសង្គមមានការរីកចម្រើន និងបរិស្ថាន ល្អ។ ចំណុច ប្រសព្វនេះធ្វើឲ្យមានការចូលរួមគ្រប់គ្រង និង បែងចែកផលប្រយោជន៏ធន ធាន ធម្មជាតិដូចគ្នា រវាងមនុស្សនៅក្នុងសង្គមក៏ប៉ុន្តែមានការផ្តោតទៅលើការទាញយកធន ធានសម្រាប់អភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចមានកម្រិតតិចតួចនិងការអភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធ មិនមានការរីកចម្រើនដែរ។ ដូចនេះចំណុចប្រសព្វនៃផ្នែកពីរនេះមិនអាចធ្វើឲ្យការគ្រប់គ្រង ធនធានធម្មជាតិមាននិរន្តរភាពបានទេ។

❖ ***ចំណុចប្រសព្វរវាងសង្គមនិងសេដ្ឋកិច្ចៈ*** មានន័យថាសង្គមនិងសេដ្ឋកិច្ចមានការរីកចម្រើន ដោយមានហេដ្ឋារចនាសម្ព័ន្ធល្អ ទំនាក់ទំនងសង្គមកាន់តែប្រសើរ ប្រជាពលរដ្ឋ មានប្រាក់ចំ ណូលខ្ពស់ ក៏ប៉ុន្តែ បរិស្ថានមិនត្រូវបានគេយកចិត្តទុកដាក់ការពារនិង ថែរក្សាទេ ព្រោះធន ធានធម្មជាតិត្រូវបានទាញយកផលសម្រាប់អភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចខ្លាំងពេក។ ដូចនេះ ចំណុចប្រសព្វនៃផ្នែកពីរនេះក៏មិនអាចធ្វើឲ្យការគ្រប់គ្រងធនធានធម្មជាតិមាននិរន្តរភាពដែរ

❖ ***ចំណុចប្រសព្វរវាងបរិស្ថាន និងសេដ្ឋកិច្ចៈ*** មានន័យថាបរិស្ថានត្រូវបានការពារយ៉ាងល្អប្រសើរ ធនធានធម្មជាតិសម្បូរបែបព្រមជាមួយ និង គ្នានេះសេដ្ឋកិច្ចក៏មានការរីកចម្រើនដែរតាមរយៈ ការទាញយកធនធានធម្មជាតិមកប្រើ ចំណែកឯសង្គមត្រូវបានគេយកចិត្តទុកដាក់តិចតួច ក្នុងដំណើរការអភិវឌ្ឍ។ សង្គមដូចជាការកសាងរចនាសម្ព័ន្ធសង្គម ទំនាក់ទំនងប្រជាពលរដ្ឋ ការបែងចែកផលប្រយោជន៏មិនមានសមធម៌។ ដូចនេះការអភិវឌ្ឍន៏ទាំងពីរនេះមិនអាចធ្វើឲ្យ មាននិរន្តរភាពបានទេ។

❖ ***ចំណុចប្រសព្វរវាង សេដ្ឋកិច្ច សង្គម និង បរិស្ថាន( និរន្តរភាព)ៈ*** ចំណុចនេះជានិរន្តរភាពនៃការ គ្រប់គ្រងធនធានធម្មជាតិដោយមានការរួមបញ្ចូលគ្នានូវផ្នែកទាំងបីនេះ។ មានន័យថាក្នុង ការគ្រប់គ្រងធនធានធម្មជាតិក៏ដូចជាការអភិវឌ្ឍដែរ ផ្នែកទាំងបីនេះត្រូវតែធ្វើការពិចារណា ឲ្យដើរស្របគ្នា។ និយាយរួមវាជាដំណើរការតតឈប់ឈរដែល ក្នុងនោះធនធាននានាត្រូវបាន គ្រប់គ្រងដើម្បីឲ្យកើតឡើងជាថ្មីសម្រាប់មនុស្សជំនាន់ក្រោយ។

## ២.៥ ទម្រង់នៃការគ្រប់គ្រងធនធានធម្មជាតិ

ការគ្រប់គ្រងធនធានធម្មជាតិអាចត្រូវបានធ្វើឡើងតាមទម្រង់ជាច្រើនយ៉ាង ទៅតាមវិធីសាស្ត្រ នៃការគ្រប់គ្រង។ ឧទាហរណ៏ៈ ធនធានអាចគ្រប់គ្រងបានទាំងស្រុងដោយរដ្ឋាភិបាល (មជ្ឈការ) ឬសហគមន៍មូលដ្ឋានផ្ទាល់ (វិមជ្ឈការ) ឬសហគ្រប់គ្រងរវាងរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន (សហគ្រប់គ្រង) ដោយមានការមានការជួយជ្រោមជ្រែងពីសំណាក់អ្នកពាក់ព័ន្ធនានា (អង្គការមិនមែន រដ្ឋាភិបាល និងម្ចាស់ជំនួយ)។ តែជាទូទៅការគ្រប់គ្រងធនធានធម្មជាតិចម្បងជារបស់រដ្ឋាភិបាល។

ការគ្រប់គ្រងធនធានធម្មជាតិអាចធ្វើឡើងតាមទម្រង់បីគឺៈ

- ❖ ការគ្រប់គ្រងបែបមជ្ឈការ
- ❖ ការគ្រប់គញគ្រងតាមបែបវិមជ្ឈការ និង
- ❖ សហគ្រប់គ្រង

## ២.៥.១ ការគ្រប់គ្រងតាមបែបមជ្ឈការ

សំដៅទៅលើវិធីសាស្ត្រគ្រប់គ្រងពីថ្នាក់លើមកថ្នាក់មូលដ្ឋាន។ រដ្ឋាភិបាលជាអ្នកគ្រប់គ្រង និងជាម្ចាស់លើធនធានធម្មជាតិ។ ជាក់ស្តែងប្រទេសកម្ពុជាក្នុងកំឡុងទសវត្សរ៍ឆ្នាំ ១៩៩០ បានអនុវត្ត របបគ្រប់គ្រងធនធានជលផល និងព្រៃឈើតាមបែបមជ្ឈការ។ ឧទាហរណ៍៖ ប្រព័ន្ធឡូត៍នេសាទ និងព្រៃគុបហ៍។

ការគ្រប់តាមបែបមជ្ឈការមិនសូវទទួលបានជោគជ័យទេ ដោយសារតែរដ្ឋាភិបាលមិនមាន លទ្ធភាពក្នុងការគ្រប់គ្រងធនធានពីចម្ងាយដែលជាហេតុធ្វើឲ្យ៖

- ❖ ខ្វះព័ត៌មាន និងចំណេះដឹងអំពីអន្តរទំនាក់ទំនងរវាងធនធានធម្មជាតិ និងសហគមន៍ មូលដ្ឋាន
- ❖ ក្របខណ្ឌច្បាប់ដែលគាំទ្រដល់ការគ្រប់គ្រងធនធានធម្មជាតិមិនទាន់ឆ្លើយតបទៅ និងការវិវឌ្ឍន៍ទៅនិងស្ថានភាព
- ❖ ខ្វះព័ត៌មានអំពីមូលដ្ឋាន និងលក្ខខណ្ឌធម្មជាតិ
- ❖ ខ្វះការចូលរួមពីប្រជាពលរដ្ឋមូលដ្ឋាន
- ❖ មានការកំណត់មិនច្បាស់លាស់ពីសិទ្ធិគ្រប់គ្រងធនធាន

## ២.៥.២ ការគ្រប់គ្រងតាមបែបវិមជ្ឈការ

វិមជ្ឈការ គឺជាដំណើរការនៃការផ្ទេរការទទួលខុសត្រូវដើម្បីរៀបចំផែនការគ្រប់គ្រងធ្វើឲ្យធនធាន មានលក្ខណៈល្អប្រសើរឡើង និងធ្វើការបែងចែកអំណាចពីរដ្ឋាភិបាលថ្នាក់កណ្តាល និងភ្នាក់ងារទៅ ក្រសួង-មន្ទីរ អាជ្ញាធរ តំបន់ឃុំ និង ភូមិព្រមទាំងសហគមន៍។

វិមជ្ឈការទទួលស្គាល់ថារដ្ឋាភិបាលថ្នាក់មូលដ្ឋាន និងអ្នកប្រើប្រាស់ត្រូវតែចូលរួមនៅក្នុង ដំណើរការគាំទ្រ ផ្នែកគោលនយោបាយ និងហិរញ្ញវត្ថុដើម្បីចូលរួមចំណែកទៅក្នុងដំណើរការនៃការធ្វើ សេចក្តីសម្រេចចិត្ត និងការអភិវឌ្ឍព្រមទាំងកំណែទម្រង់គោលនយោបាយ។

ជារួមការគ្រប់គ្រងបែបនេះសំដៅលើការគ្រប់គ្រងពីក្រោមឡើងលើ ដែលមានការចូលរួមពី សំណាក់អ្នកពាក់ព័ន្ធ ជាពិសេស គឺសហគមន៍មូលដ្ឋានដោយធ្វើការផ្ទេរអំណាចជូនប្រជាពលរដ្ឋ ដើម្បីឲ្យពួកគាត់គ្រប់គ្រងធនធានដោយខ្លួនឯង។

នៅប្រទេសកម្ពុជាកម្មវិធីសិលាជំហានទី២ ឆ្នាំ២០០៣ បានអនុវត្តកម្មវិធីការគ្រប់បរិស្ថាន និង ធនធានធម្មជាតិដោយបានធ្វើការបញ្ជ្រៀបយុទ្ធសាស្ត្រដើម្បីគាំទ្រដល់ការគ្រប់គ្រងបរិស្ថាន និងធន

ធានធម្មជាតិនៅបឹកម្រិត របស់រដ្ឋាភិបាល (ថ្នាក់ជាតិ ថ្នាក់ខេត្ត និងឃុំ)។ ការគ្រប់គ្រងធនធានធម្មជាតិតាមបែបវិមជ្ឈការ ត្រូវបានទទួលស្គាល់ថាជាការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍។

ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ នៅប្រទេសកម្ពុជា គឺជាការអនុវត្តការគ្រប់គ្រងធនធានធម្មជាតិតាមបែបវិមជ្ឈការ ដែលប្រជាពលរដ្ឋមូលដ្ឋានចូលរួមធ្វើការគ្រប់គ្រប់គ្រងធនធានធម្មជាតិនៅក្នុងមូលដ្ឋានរបស់ខ្លួន ។

"ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ទទួលស្គាល់ថា សហគមន៍មូលដ្ឋាន គឺជាអ្នកដែលមានតួនាទីសំខាន់ក្នុងការកំណត់ធនធាន កំណត់អាទិភាពអភិវឌ្ឍន៍ ជ្រើសរើស និងសម្របតាមបច្ចេកវិទ្យា និងអនុវត្តលើការគ្រប់គ្រង"។

ក្នុងបរិបទនៃប្រទេសកម្ពុជា ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ត្រូវបានគេកំណត់ថាជា "ភាពចម្រុះគ្នានៃវិធីសាស្ត្រសហគ្រប់គ្រងដែលខិតខំធ្វើការផ្តល់អំណាចដល់សហគមន៍មូលដ្ឋានដើម្បីចូលរួមយ៉ាងសកម្មក្នុងការៈអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាពតាមរយៈយុទ្ធសាស្ត្រផ្សេងៗគ្នារួមទាំងសហគមន៍ព្រៃឈើ សហគមន៍នេសាទ ការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងតំបន់ធម្មជាតិដែលមានការចូលរួម" (វិទ្យស្ថាន CBNRMLI, 2005)។

ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ គឺជាជម្រើសមួយដែលជួយឲ្យសហគមន៍ និងរដ្ឋាភិបាលការពារប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព។ ទាំងសហគមន៍ និងរដ្ឋាភិបាលទទួលផលប្រយោជន៍ពីការធ្វើការរួមគ្នា។ បន្ថែមពីនេះទៀតការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍រួមបញ្ចូលអ្នកពាក់ព័ន្ធទាំងអស់ជាពិសេស គឺក្រុមជនក្រីក្រ និងក្រុមដែលសង្គមមិនសូវផ្តលឱកាសឲ្យទៅក្នុងដំណើរការរៀបចំគោលនយោបាយ និងការធ្វើសេចក្តីសម្រេចចិត្ត។

ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ អាចប្រព្រឹត្តទៅបានដោយមានការអនុវត្តវិធីសាស្ត្រដែលមានការចូលរួម។ វិធីសាស្ត្រដែលមានការចូលរួមក្នុងការគ្រប់គ្រងធនធានធម្មជាតិ គឺជាដំណើរការនៃការបង្កើនការចូលរួមរបស់អ្នកពាក់ព័ន្ធមូលដ្ឋានក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងការធ្វើការសម្រេចដោយរួមបញ្ចូលក្រុមភាគតិច និងក្រុមដែលសង្គមមិនសូវផ្តល់ឱកាសឲ្យ។ ម្យ៉ាងទៀតវិធីសាស្ត្រនេះជួយពង្រឹងសមត្ថភាពរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានតាមរយៈការចូលរួមយ៉ាងសកម្មរបស់ពួកគាត់ក្នុងគម្រោង និងកម្មវិធីអភិវឌ្ឍព្រមទាំងការអនុវត្តដែលជាញឹកញាប់មានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល អ្នកជំនាញ ឬមន្ត្រីរដ្ឋាភិបាល ។

ដើម្បីបង្កើនឱ្យមានការចូលរួមលើការគ្រប់គ្រងធនធានធម្មជាតិការអនុវត្តវិធីសាស្ត្រដែលមានការចូលរួម ត្រូវធ្វើឡើងដោយមាន៖

- ***<u>ការរៀបចំសហគមន៍ ៖</u>*** ធានាថាការរៀបចំសហគមន៍ធ្វើឡើងក្នុងគោលបំណងច្បាស់

លាស់។ ម៉្យាងទៀតលទ្ធផលនៃការរៀបចំសហគមន៍ត្រូវផ្តល់ផលប្រយោជន៍ផ្ទាល់ដល់សមាជិកសហគមន៍ដើម្បីជំរុញឱ្យមានការចូលរួមយ៉ាងពេញលេញពីសហគមន៍ ការផ្តល់សិទ្ធិអំណាចដល់សហគមន៍ និងការអភិវឌ្ឍសហគមន៍។ ការប្រើប្រាស់វិធីសាស្ត្រដែលមានការចូលរួមដើម្បីឱ្យប្រជាពលរដ្ឋកំណត់ពីបញ្ហាតម្រូវការ និងយុទ្ធសាស្ត្រក្នុងការដោះស្រាយដើម្បីទទួលបានផលប្រយោជន៍។

- ***ការផ្តល់សិទ្ធិអំណាច៖*** ការផ្តល់សិទ្ធិអំណាចមានន័យថា សាធារណៈជន ឬក្រុមមួយមានសិទ្ធិ អំណាចយ៉ាងទូលំទូលាយទៅលើការត្រួតពិនិត្យលើស្ថានភាពដែលគេកំពុងរស់នៅ។ ការផ្តល់សិទ្ធិ អំណាច គឺជាទម្រង់មួយដែលមានការចូលរួមយ៉ាងពេញលេញ ព្រោះថាសហគមន៍ គឺជាអ្នកកំណត់ និងដោះស្រាយបញ្ហាព្រមទាំងអនុវត្តការគ្រប់គ្រងដោយខ្លួនឯង។ ការផ្តល់សិទ្ធិអំណាច គឺជាការបញ្ចូលសហគមន៍ដើម្បីធ្វើការគ្រប់គ្រងធនធាននៅមូលដ្ឋានដែលពួកគេប្រើប្រាស់ ជាជាងពឹងផ្អែកទៅលើរដ្ឋដែលពុំអាចមានលទ្ធភាពគ្រប់គ្រាន់ដើម្បីពង្រឹងការអនុវត្តច្បាប់បាន។

  **ឧទាហរណ៍៖** នៅក្នុងប្រទេសកម្ពុជាវិធីសាស្ត្រដែលមានការចូលរួមត្រូវបានអនុវត្តតាមរយៈសហគមន៍ព្រៃឈើ សហគមន៍នេសាទ សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ទេសចរណ៍ធម្មជាតិ និងផែនការប្រើប្រាស់ដីធ្លីដែលមានការចូលរួម។

## ២.៥.៣ សហគ្រប់គ្រង

### តើសហគ្រប់គ្រងជាអ្វី?

សហគ្រប់គ្រង គឺជាដំណើរការមួយដែលសហគមន៍មូលដ្ឋានរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានាធ្វើការរួមគ្នាដើម្បីគ្រប់គ្រងធនធានធម្មជាតិ។ នេះមានន័យថាត្រូវតែមានការចែករំលែកអំណាចរវាងស្ថាប័នរដ្ឋាភិបាល និងប្រជាពលរដ្ឋ។ សហគ្រប់គ្រងផ្តោតទៅលើដំណើរការគ្រប់គ្រងពីក្រោមឡើងលើជាជាងដំណើរការគ្រប់គ្រងពីលើចុះក្រោម។ លើសពីនេះសហគ្រប់គ្រងក៏ផ្តោតផងដែរទៅលើការចូលរួមរបស់ក្រុមអ្នកប្រើប្រាស់ ព្រោះថាការចូលរួមនេះមានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើសេចក្តីសម្រេចរួមគ្នារវាងអ្នកប្រើប្រាស់ និងអ្នកគ្រប់គ្រងធនធាន។

សហគ្រប់គ្រងត្រូវបានពិពណ៌នាថាជាជាដំណើរការទូទៅ និងអាចអនុវត្តន៍បន្តបាន ដើម្បីចែករំលែកការគ្រប់គ្រង និងការទទួលខុសត្រូវរបស់រដ្ឋាភិបាល និងក្រុមអ្នកប្រើប្រាស់ក្នុងការធ្វើសេចក្តីសម្រេចតាមបែបវិមជ្ឈការដើម្បីលើកកម្ពស់ការគ្រប់គ្រងធនធានធម្មជាតិ ផ្តល់ការសម្របសម្រួលអព្យាក្រឹត្យ និងជំរុញឱ្យមានការពិភាក្សារវាងអ្នកពាក់ព័ន្ធ (Hartmann, 2000)។




**រូបភាពទី ៨ ៖ រូបភាពឋានានុក្រមនៃការរៀបចំសហគ្រប់គ្រងចលផល (Berkes ១៩៩៤)**

ឧទាហរណ៍ពីសហគ្រប់គ្រងក្នុងការគ្រប់គ្រងធនធានជលផល ៖ នៅក្នុងឆ្នាំ២០០០ នាយករដ្ឋមន្ត្រីបានបញ្ជាឱ្យមានកំណែទម្រង់វិស័យជលផល ហើយរដ្ឋាភិបាលបានកាត់ឡូត៍នេសាទ ចំនួន ៥៦.២៣ ភាគរយនៃដែនឡូត៍នេសាទសរុបឱ្យទៅសហគមន៍មូលដ្ឋាន។ នេះគឺជាកំណែទម្រង់មួយក្នុងវិស័យជលផល និងការគ្រប់គ្រងជលផលតាមបែបវិមជ្ឈការទៅឱ្យសហគមន៍មូលដ្ឋាន។ សហគមន៍នេសាទភាគច្រើនត្រូវបានបង្កើតឡើងនៅកន្លែងដែលបានកាត់ឡូត៍នេសាទចេញ (DoF, 2001)។ នៅឆ្នាំ ២០០២ មានសហគមន៍នេសាទប្រហែល ២៦៤ត្រូវបានបង្កើតឡើងនៅទូទាំងកម្ពុជា ហើយសហគមន៍ភាគច្រើននៅជុំវិញបឹងទន្លេសាប។ កាលពីខែមិថុនា ឆ្នាំ២០០៥ ព្រះរាជក្រឹត្យ ស្តីពីសហគមន៍នេសាទ និងអនុក្រឹត្យស្តីពីសហគមន៍នេសាទ ត្រូវបានអនុម័ត និងចូលជាធរមានហើយនៅ ខែឧសភាឆ្នាំ ២០០៦ ច្បាប់ស្តីពីជលផលក៏ត្រូវបានឡាយព្រះហស្ថលេខា ដោយព្រះមហាក្សត្រផងដែរ។

ដើម្បីឱ្យដំណើរការសហគ្រប់គ្រងទទួលបានជោគជ័យ លោក ហាតមែន (Hartmann) បាន

ពិចារណាលើ ៤ ចំណុចសំខាន់ៗគឺ ៖

- ***ការគ្រប់គ្រងធនធានធម្មជាតិ ៖*** សំដៅលើសកម្មភាពនានាដើម្បីគ្រប់គ្រង ការពារ អភិរក្ស ស្តារឡើងវិញ ក្របខណ្ឌច្បាប់ និងការកែលំអធនធានធម្មជាតិ។
- ***ការអភិវឌ្ឍសហគមន៍និងសេដ្ឋកិច្ច ៖*** សំដៅលើការបង្កើនប្រាក់ចំណូលការកែលំអកម្រិតជីវភាពរស់នៅ និងលើកកម្ពស់សេវាសង្គមរួមមានហេដ្ឋារចនាសម្ព័ន្ធនិងបង្កើនការប្រាស្រ័យទាក់ទងនៅក្នុងសង្គម។
- ***ការកសាងសមត្ថភាព ៖*** សំដៅលើការកសាងសមត្ថភាពរបស់អ្នកពាក់ព័ន្ធជាពិសេស គឺប្រជា-ពលរដ្ឋ មូលដ្ឋានទាក់ទងនឹងការចូលរួម ការផ្តល់អំណាចក្នុងចំណោមប្រជាពលរដ្ឋ ការអប់រំ និងបណ្តុះបណ្តាល។
- ***ការគាំទ្រស្ថាប័ន និងគោលនយោបាយ ៖*** ពាក់ព័ន្ធនឹងយន្តការគ្រប់គ្រងទំនាស់ ចំណងទាក់ទងរវាង បុគ្គល និងស្ថាប័ន ការរៀនសូត្របទពិសោធន៍ពីគ្នាទៅវិញទៅមក ការគាំទ្រខាងផ្នែកច្បាប់ ការកសាងគោលនយោបាយ ការតស៊ូមតិ និងបណ្តាញការងារ វេទិកានានាសម្រាប់ចែករំលែកបទពិសោធន៍ និងការចែករំលែកអំណាច (Hartmann, 2000)។

# មេរៀនទី ៣ ៖ សំណងលើសេវាកម្មបរិស្ថាន

## ៣.១ ទស្សនទាននៃសំណងលើសេវាកម្មបរិស្ថាន

សេវាកម្មបរិស្ថានផ្តល់ដល់សង្គម នូវសេវាកម្មជាច្រើន ដូចជាទឹកស្អាត ការបង្កបង្កើត ដី ហើយ និងការស្រូបយកឥណទានកាបូន។ មនុស្ស ក្រុម ហ៊ុន សង្គម ពឹងពាក់អាស្រ័យនូវសេវាកម្មទាំងនេះ សម្រាប់វត្ថុធាតុដើម ដំណើរការផលិត ហើយនិងការរក្សាលំនឹងអាកាសធាតុ និងការទប់ស្កាត់ ការីករាលដាលនៃជំងឺ និងគ្រោះធម្មជាតិជា ច្រើនទៀត។

ដូចនេះសេវាកម្មបរិស្ថាន គឺជាដំណើរដែលបរិស្ថានបានផ្តល់ឲ្យយើងនូវធនធានប្រើប្រាស់ ដូច ជា ទឹក ដើមឈើ ទីជម្រកសម្រាប់មច្ឆា ហើយនិងដំណើរលំអងសម្រាប់រុក្ខជាតិព្រមទាំងធន។

### ៣.១.១ សំណងលើសេវាកម្មបរិស្ថាន

តើអ្វីទៅជាសំណងលើសេវាកម្មបរិស្ថាន?

សំណងលើសេវាកម្មបរិស្ថាន ជាបរិបទថ្មីមួយនៅលើពិភពលោក។

សំណងលើសេវាកម្មបរិស្ថាន គឺជាដំណើរការស្ម័គ្រចិត្តមួយសម្រាប់ការរៀបចំសេវាកម្មបរិស្ថាន អោយមានលក្ខណល្អប្រសើរតាមបែបបទផ្សេងៗ។ សំណងលើសេវាកម្មបរិស្ថាន គឺជាឧបករណ៍ សេដ្ឋកិច្ចមួយដែលត្រូវបានគេបង្កើតឡើងដើម្បី លើកទឹកចិត្តដល់អ្នកប្រើប្រាស់ដីដែលជាអ្នកទទួល ផលប្រយោជន៍សម្រាប់ដីកសិកម្មតំបន់ឆ្នេរ ឬក៏ការគ្រប់គ្រងសមុទ្រដែលជាលទ្ធផលត្រូវបានគេរំពឹង ថាជាផលដែលនៅតែមានបន្ត□និងការផ្តល់ឲ្យសេវាកម្មបរិស្ថានកាន់តែប្រសើរឡើង□ ដែលធ្វើអោយ អ្នកប្រើប្រាស់ផ្ទាល់ និងសង្គមទទួលផលកាន់តែច្រើនឡើង។ បច្ចុប្បន្ននេះ□ទម្រង់ការនៃសំណង លើសេវាកម្មបរិស្ថាន គឺផ្តោតទៅលើ ទឹក កាបូន ឬក៏ជីវចម្រុះ និងមានលក្ខណៈជាសាធារណៈ។ ប៉ុន្តែផ្នែកផ្នែកវិស័យឯកជនក៏ចាប់អារម្មណ៍ទៅលើ□ បញ្ហាបរិស្ថានតាមរយៈការផ្តល់ប្រាក់លើកទឹកចិត្ត ទៅដល់ម្ចាស់ដី។

តើអ្នកក្រទទួលបានផលប្រយោជន៍អ្វីខ្លះពីសំណងលើសេវាកម្មបរិស្ថាន?

ភាពក្រីក្រ គឺជាបញ្ហាមួយដែលសំខាន់មួយដែលធ្វើឲ្យមានការហិនហោចដល់បរិស្ថាន។ សំណងលើសេវាកម្មបរិស្ថានមិនត្រូវបានបង្កើតឡើងដើម្បីកាត់បន្ថយភាពក្រីក្រទេ។ ប៉ុន្តែសំណងលើ សេវាកម្មបរិស្ថាន វាបានផ្តល់ឲ្យប្រាក់ចំណេញដល់សេដ្ឋកិច្ច ដែលមានលក្ខណៈងាយស្រួល ហើយ និងការប្រើ សេវាកម្មបរិស្ថានប្រកបដោយចិរភាព។

ទោះបីជាយ៉ាងណាក៏ដោយ ក៏មានឱកាសជាច្រើនក្នុងការរៀបចំសំណងលើសេវាកម្មបរិស្ថាន ដែលអាចមាន ប្រយោជន៍ដល់អ្នកដែលមានប្រាក់ចំណូលទាបអាចរកប្រាក់កម្រៃដោយការលើក កម្ពស់ និងអភិរក្សប្រព័ន្ធអេកូឡូស៊ី។ នេះគឺជាការលក់ដូមួយដែលមានការគិតល្អិតល្អន់។ ពីព្រោះ

ប្រជាជនជនជា ច្រើនប្រកបមុខរបរដោយពឹងពាក់លើធនធានធម្មជាតិ ដូចជាព្រៃឈើ ការធ្វើកសិកម្ម។ ការប្រើប្រាស់ព្រៃឈើ និងការធ្វើកសិកម្មហួសកម្រិត គឺជាប្រាក់រង្វាន់ដែលមានរយៈពេលខ្លី។ នៅក្នុងបរិបទជាក់ស្តែងមួយសំណាងលើសេវាកម្មបរិស្ថាន អាចបង្ហាញនូវប្រាក់រង្វាន់ថ្មី សម្រាប់ការគ្រប់គ្រងដែលមាននិរន្តរភាពនៅក្នុងលក្ខខណ្ឌជាប្រព័ន្ធនៃសេវាកម្មបរិស្ថាន។ សំណាងលើសេវាកម្មបរិស្ថានដែលមានលក្ខណៈបង្គាប់ បញ្ហានេះអាច លើកកម្ពស់អោយមានការប្រើប្រាស់ធនធានបានយូរអង្វែង។

### ៣.១.២ ប្រភេទនៃសេវាកម្មបរិស្ថាន

- ការផ្តល់ឲ្យនៃសេវាកម្មបរិស្ថាន៖ អាហារ ទឹកស្អាត ឈើ និងឥន្ទនៈ
- ការទ្រទ្រង់៖ ការវិវឌ្ឍ លូតលាស់ វដ្តនៃសារធាតុចិញ្ចឹម និងការបង្កបង្កើតដី
- សេវាកម្ម ការរក្សាលំនឹង៖ សេវាកម្ម បរិស្ថាន អាចរក្សាបាន នូវលំនឹង អាកាសធាតុ ទឹកជំនន់ ការរីករាលដាលនៃជំងឺ
- សេវាកម្មវប្បធម៌៖ សេវាកម្មបរិស្ថានក៏អាចផ្តល់នូវ លក្ខណៈសោភ័ណ្ឌ ព្រលឹងដូនតា ការកំសាន្ត និងការអប់រំ។

បើទោះបីជាសេវាកម្មបរិស្ថានមានតម្លៃថ្លៃថ្នាយ៉ាងណាក៏ដោយ សេវាកម្មបរិស្ថានមិនទាន់ត្រូវបានគេឲ្យតម្លៃជាទឹកប្រាក់នៅឡើយទេ។ តួយ៉ាងដូចជាពេលបច្ចុប្បន្នអ្នកធ្វើការសម្រេចចិត្តខាងការអភិវឌ្ឍគិតតែទៅលើអ្វីដែលផ្តល់ជាលុយភ្លាមៗ។ ប្រព័ន្ធអេកូស៊ីស្តែម និងមុខងាររបស់វាត្រូវបានគេអោយតម្លៃទាប។ ការប៉ាន់ប្រមាណសេវាកម្មបរិស្ថានថ្មីបំផុត (ការប៉ាន់ប្រមាណអេកូស៊ីស្តែមសហស្សវត្ស-MEA) ធ្វើឡើងដោយអ្នកវិទ្យាសាស្ត្រជាង ១៣០០ ដែលមកពីប្រទេសចំនួន ៩៥ ប្រទេសបានរកឃើញថា សេវាកម្មបរិស្ថានជាង ៦០ភាគរយ បានបាត់បង់លឿនជាងការបង្កើតឡើងវិញ។

ដើម្បីឆ្លើយតបទៅនិងក្តីបារម្ភណ៍ដ៏ធំធេងនេះ ទីផ្សារសម្រាប់អេកូស៊ីស្តែមមានការលេចឡើងជាច្រើននៅក្នុងបណ្តាប្រទេសជាច្រើននៅលើពិភពលោក។ ទីផ្សាផ្លូវការ (ទីផ្សារស្ម័គ្រចិត្ត និងទីផ្សារកំណត់ដោយច្បាប់រដ្ឋត្រូវបានគេបង្កើតឡើងហើយ ទាក់ទង និងឧស្ម័នផ្ទះកញ្ចក់ ឬកាបូន ទឹក ហើយ និងជីវចម្រុះ)។

### ៣.១.៣ ទម្រង់នានានៃសំណងលើសេវាកម្មបរិស្ថាន

តើមានជម្រើសយ៉ាងដូចម្តេចខ្លះក្នុងការធ្វើសំណងលើសេវាកម្មបរិស្ថាន?
ទម្រង់នៃការសងទៅលើសេវាកម្មបរិស្ថានមានបែបទបផ្សេងៗគ្នា៖

❖ ការសងជាលុយផ្ទាល់

ជាទូទៅការសងជាប្រាក់ គឺសងដើម្បីជំនួសថ្លៃឳកាសលក្ខណៈនេះវាបានធ្វើឲ្យប៉ះពាល់ដល់ការចិញ្ចឹមជីវិតដោយសារតែយើងការពារសេវាកម្មបរិស្ថាន។

❖ ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធដល់តំបន់គោលដៅនៅក្នុងសហគមន៍

យើងផ្តល់ដល់ពួកគាត់ដូចជាអាគារ មណ្ឌលសុខភាព សាលារៀន

❖ ការចំណាយដោយស្ម័គ្រចិត្ត (ការជួយជាសម្ភារផ្សេងៗដូចជា គោយន្ត.........)

❖ ការទទួលស្គាល់សិទ្ធិ

ដូចជាពង្រីកឲ្យមានកម្មសិទ្ធដីធ្លី និងបង្កើនការចូលរួមក្នុងដំណើរការនៃការសម្រេចចិត្ត (ការបែងចែកទំហំដីជាក់លាក់ណាមួយជូនអ្នកផ្តល់សេវាកម្ម)។

## ៣.១.៤ ដំណាក់កាលនៃការរៀបចំសំណងលើសេវាកម្មបរិស្ថាន

ដំណាក់កាល ទី ១ ៖ កំណត់នូវតម្រូវការ កំណត់គោលបំណង និងកំណត់តម្លៃ

- ការពិនិត្យឡើងវិញពីបរិបទសេដ្ឋកិច្ចសង្គម តម្រូវការសម្រាប់សេវាកម្មបរិស្ថានជាក់លាក់ពីអ្នកទិញ( ពានិជ្ជករ ឬ អ្នកទិញជាបុគ្គល)
- កំណត់វាស់វែង និង ប៉ាន់តម្លៃពិតប្រាកដនៃសេវាកម្មបរិស្ថាន និងកំណត់ពីការគំរាមកំហែងពេលបច្ចុប្បន្នក៏ដូចជាពេលអនាគត
- កំណត់ឲ្យច្បាស់ថាតើ□សំណងលើសេវាកម្មបរិស្ថានជាឧបករណ៍នយោបាយ ឬក៏អ្វីដែលជាតម្រូវការចាំបាច់
- កំណត់ពីគោលបំណង
- កំណត់តម្លៃសេដ្ឋកិច្ច និងតម្លៃទីផ្សារតាមរយៈការវាយតម្លៃផ្ទាល់ពីតម្លៃបរិស្ថាន

ដំណាក់កាល ទី ២ ៖ ស្ទង់មើលស្ថាប័ន និងលទ្ធភាពបច្ចេកទេស

- ប៉ាន់ប្រមាណគោលនយោបាយ និងភាពជាម្ចាស់ដី
- ពិនិត្យមើលគោលនយោបាយដែលមានទាក់ទងនឹងសំណងលើសេវាកម្មបរិស្ថាន ម្ចាស់ដី គួរតែបានទទួលនូវសំណងហើយអ្នកទិញត្រូវតែមានសំណង ( ហើយប្រសិនបើចាំបាច់ត្រូវគិតថ្លៃ ឬ ពន្ធដែលត្រូវបានគេប្រើ គួរតែគិតថ្លៃបញ្ចូលទៅក្នុងកម្មវិធីសំណងលើសេវាកម្មបរិស្ថាន។

ដំណាក់ការ ទី ៣ ៖ ការបង្កើតស្ថាប័ន ក្របខណ្ឌកិច្ចសន្យា

- រៀបចំគម្រោង និងផែនការធ្វើជំនួញ
- កំណត់នូវក្របខណ្ឌស្ថាប័នដោយផ្អែកទៅលើស្ថាប័នដែលមានស្រាប់ និងរកវិធីសាស្ត្រផ្សេងៗទៀតដើម្បីកាត់បន្ថយតម្លៃប្រតិបត្តិការ ព្រមទាំងបង្កើនសមត្ថភាព ទៅតាមតម្រូវការ។
- កំណត់ពីប្រសិទ្ធភាព និងវិធីសាស្ត្រដែលត្រឹមត្រូវក្នុងការសង ដោយផ្អែកទៅលើសេដ្ឋកិច្ចសង្គម និងសង្គមវប្បធម៌។
- រៀបចំនូវគំរូកិច្ចសន្យា និងដំណើរការរៀបចំឯកសារផ្សេងៗទៀត។

ដំណាក់កាល ទី ៤ ៖ ការអនុវត្ត

- ទំនាក់ទំនង ទីផ្សារ ការចចារ ហើយ និងការចុះកិច្ចសន្យា
- ដំណើរការត្រួតពិនិត្យ និងធ្វើការផ្ទៀងផ្ទាត់
- ដំណើរការរៀបចំថវិការ និងសំណង

## ៣.១.៥ បទពិសោធន៍នានានៃសំណងលើសេវាកម្មបរិស្ថាន

**ប្រទេសវៀតណាម (គម្រោងគ្រប់គ្រងទីជម្រាល)**

វៀតណាម គឺជាប្រទេសអាស៊ីខាងត្បូងទីមួយដែលបានដំណើរការគោលនយោបាយសាកល្បកថ្នាក់ជាតិស្តីពីសំណងលើសេវាកម្មបរិស្ថានព្រៃឈើ។ ខេត្តឡាមដូង ស្ថិតភាគខាងលើនៃអាងទន្លេដួងណៃ ហើយមានគម្របព្រៃជាង ៦០ភាគរយ ត្រូវបានជ្រើសរើសជាតំបន់សម្រាប់គម្រោងសាកល្បងនៅក្នុងឆ្នាំ២០០៧។ ខណៈដែលគម្របព្រៃដែលផ្តល់ដោយខេត្តឡាមដូង ត្រូវបានចាត់ទុកថាមានសក្តានុពលដើម្បីការពារធនធានទឹក ក៏ដូចជាសម្រាប់អភិរក្សជីវះចម្រុះ ខេត្តនេះ មានផលិតផលជាតិសរុបសម្រាប់ម្នាក់ៗទាប និងមានអត្រាភាពក្រីក្រខ្ពស់បើធៀបទៅនឹងបណ្តាខេត្តដទៃទៀត។

កំឡុងពេលដំណើរការនូវគោលនយោបាយសាកល្បងនេះ ដែលបាប់ផ្តើមខែមេសា ឆ្នាំ២០០៨ ដីព្រៃច្រើនជាង៣០០០០០ហិចតា ត្រូវបានចុះកិច្ចសន្យាជាមួយប្រជាជន ១៤០០០ គ្រួសារ ដើម្បីធ្វើការគ្រប់គ្រងប្រកបដោយនិរន្តភាព។ គម្រោងបានធានានូវកម្រិតចូលរួមយ៉ាងខ្ពស់ ដោយប្រើប្រាស់នូវប្រព័ន្ធផ្សព្វផ្សាយទំនាក់ទំនង ដូចជា វិទ្យុ និងទូរស្សន៍ជាដើម។ ដោយមានការគាំទ្រថវិការពី USAID កម្មវិធីអភិរក្សជីវះចម្រុះតំបន់អាស៊ី បានគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍគោលនយោបាយ ផ្តល់វគ្គបណ្តុះបណ្តាល និងសាបព្រោះចំណេះដឹងនានា។

អ្នកទិញសំខាន់ៗនៃសេវាកម្មបរិស្ថានមានដូចជា ក្រុមហ៊ុនវារីអគ្គិសនី ភ្ញៀវទេសចរណ៍ និងឧស្សាហកម្មទឹកបរិសុទ្ធ។ ក្រុមហ៊ុនទេសចរណ៍ធម្មជាតិ ត្រូវបានស្នើរអោយបង់១ភាគរយនៃចំណូលសរុបរបស់ពួកគេ ក្នុងការបតទៅនឹងសេវាកម្មបរិស្ថានព្រៃឈើទាក់ទងទៅនឹងភាពស្រស់ស្អាបនៃធម្មជាតិ។ ក្រុមហ៊ុនវារីអគ្គិសនី និងឧស្សាហកម្មទឹកបរិសុទ្ធ ដែលប្រើប្រាស់ទឹកពីអាងទន្លេដូងណៃ ត្រូវបានគេសង្ឃឹមទុកថានឹងវិនិយោគទឹកប្រាក់ប្រមាណជា ៣លានដុល្លារ ក្នុងមួយឆ្នាំ ដើម្បីការពារផលិតភាពជានិរន្តនៃវារីអគ្គសនី ការផ្គត់ផ្គងទឹក និងគុណភាពទឹក។ ជាមួយនឹងការជួយជ្រោមជ្រែងពីគម្រោងថវិការអភិវឌ្ឍ និងការពារព្រៃឈើឡាមដួង រដ្ឋភិបាលបានធានានូវការផ្សព្វផ្សាយដ៏យុត្តិធម៌ស្តីពីថវិការ ដែលទទួលបានដល់អ្នកផ្តល់សេវាកម្ម មានដូចជា គ្រួសារ និងសហគមន៍ដែលបានចូលរួម។

**ប្រទេសកម្ពុជា (គម្រោងអភិរក្សជីវចម្រុះ និងទេសចរណ៍ធម្មជាតិ)**

កម្ពុជា បានបង្ហាញនូវឧទាហរណ៍ដ៏ល្អមួយទាក់ទងនឹងគម្រោងអភិរក្សជីវៈចំរុះសីម៉ា ខេត្តមណ្ឌលគិរី។ គម្រោងបានចាប់ផ្តើមនៅឆ្នាំ២០០២ ដោយចំណាយដល់ប្រជាជនមូលដ្ឋានក្នុងការថែរក្សាសម្រុកសត្វស្លាប ដើម្បីដោះស្រាយការគម្រាមគំហែងនានាដែលកើតមានចំពោះប្រភេទជិតផុតពូជ។ ក្នុងនាមជាស្ថាប័នសម្របសម្រួល សមាគមន៍អភិរក្សសត្វព្រៃបានចុះកិច្ចសន្យា និងបានចំណាយដល់ប្រជាជនមូលដ្ឋានទាក់ទងទៅនឹងចំនួនសម្រុកដែលបានការពារ។ ដោយចាប់ផ្តើមដំបូងក្នុងភូមិចំនួន៤ នៅឆ្នាំ២០០២ ហើយ៦ឆ្នាំក្រោយមកគម្រោងបានពង្រីងដល់ភូមិចំនួន២១ ដោយការពារបាន ១៥០០ សម្រុក។

នៅតំបន់អង្គរក្នុងប្រទេសកម្ពុជា សមាគមន៍អភិរក្សសត្វព្រៃ និងមជ្ឈមណ្ឌលសមវាសនា (អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក) បានផ្តួចផ្តើមបង្កើតជាគម្រោងទេសចរណ៍ធម្មជាតិ ដោយមានការសហការជាមួយសហគមន៍មូលដ្ឋាន និងក្រុមហ៊ុនទេសចរណ៍ធម្មជាតិ។ តំបន់បានទទួលនូវការចាប់អារម្មណ៍ជាពិសេសពីសំណាក់អ្នកទស្សនាសត្វស្លាប ប៉ុន្តែការបរបាញ់ និងការបំផ្លាញព្រៃឈើ ជាកត្តាគម្រាមគំហែងដល់ប្រភេទបក្សីកម្រ។ ស្ថិតក្រោមគម្រោងទេសចរណ៍ធម្មជាតិដោយមានការចូលរួមពីសហគមន៍ អ្នកភូមិបានចុះកិច្ចព្រមព្រៀងក្នុងការហាមបរបាញ់ និងទទួលយកផែនការប្រើប្រាស់ដីដោយមានការគាំទ្រពី រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល។ ក្នុងការបតស្នងមកវិញ ថវិការចំនួន ៤០០០ដុល្លារ/ភូមិ ត្រូវបានផ្តល់ជូន ដោយត្រូវបានចាត់ទុកថា ជាប្រភពចំណូលសំខាន់បំផុតនៅក្នុងតំបន់។ ដោយសម្រេចបាននូវគោលបំណងសំខាន់ៗចំនួនពីរ គឺការអភិរក្សជីវៈចម្រុះ ក៏ដូចជាការកាត់បន្ថយភាពក្រីក្រ មជ្ឈមណ្ឌល សមវាសនា បានឈ្នះពាន់រង្វាន់អេក្វាទ័រសម្រាប់ការកាត់បន្ថយភាពក្រីក្រ នៅឆ្នាំ២០០៨ និងពាន់រង្វាន់មួយទៀត គឺទេសចរណ៍ព្រៃអាស៊ី នៅឆ្នាំ២០០៧។

**ប្រទេសចិន និងប្រទេសឥណ្ឌូនេស៊ី (គម្រោងគ្រប់គ្រងទីជម្រាល)**

គម្រោងអភិវឌ្ឍទីជម្រាល និងព្រៃឈើ បានទាក់ទាញនូវការចាប់អារម្មណ៍យ៉ាងពិសេសពីសំណាក់សហគមន៍ រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធដទៃទៀត។ ក្រៅពីផ្តល់នូវសេវាកម្មដូចទឹកស្អាត កាត់បន្ថយសំនឹកដី និងអភិរក្សជីវៈចម្រុះ គម្រោងក៏បានបង្ហាញនូវផលប្រយោជន៍យ៉ាងទូលំទូលាយទាក់ទងនឹងសង្គម និងសេដ្ឋកិច្ច។

ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃទឹកជំនន់ដែលមានភាពធ្ងន់ធ្ងរ និងញឹកញាប់នៅក្នុងប្រទេសចិន រដ្ឋាភិបាលចិនបានចាប់ដំណើរការកម្មវិធីបរិវត្តន៍ដីចំការជម្រាល (Sloping Farming Lands Conversion-SFLC) ក្នុងឆ្នាំ១៩៩៨។ ក្នុងគោលបំណងបង្កើនគម្របព្រៃ ពី ១០-២០ភាគរយ នៅឆ្នាំ២០១០ កម្មវិធីបរិវត្តន៍ដីចំការជម្រាល គឺជាគម្រោងធំមួយក្នុងចំណោមគម្រោងសំណងសេវាកម្មបរិស្ថាន ដែលបានអនុវត្តន៍នៅតាមបណ្តាលប្រទេសកំពុងអភិវឌ្ឍ។ រដ្ឋាភិបាលថ្នាក់កណ្តាលបានចំណាយដល់សេវាកម្មបរិស្ថានជាប្រាក់ និងគ្រាប់ពូជដំណាំ។ ជាលទ្ធផល កម្មវិធីនេះក៏ត្រូវ បានគេហៅថាគោលនយោបាយគ្រាប់ពូជដើម្បីភាពបៃតងផងដែរ។ ដោយកាត់បន្ថយនូវសំនឹកដី គម្រោងបរិវត្តន៍ដីចំការជម្រាលមិនត្រឹមតែថែរក្សានូវតួនាទីទីជម្រាលប៉ុណ្ណោះទេ ប៉ុន្តែក៏ចូលរួមថែរក្សាផលិតភាពនៃទំនប់វារីអគ្គិសនី នៅទន្លេយ៉ាងសេផងដែរ។

ទោះបីជាយ៉ាងណា ហិរញ្ញវត្ថុនៅតែជាបញ្ហានៅក្នុងគម្រោងនានា ក៏ដូចជាគម្រោងបរិវត្តន៍ដីចំការជម្រាល ដោយសារការពឹងអាស្រ័យលើការឧបត្ថម្ភគាំទ្រពីសំណាក់រដ្ឋាភិបាល។ ការឡើងថ្លៃដីក៏ជាកត្តាព្រួយបារម្មណ៍ធំមួយផងដែរសម្រាប់ការចូលរួមរបស់កសិករ។ នាពេលបច្ចុប្បន្នរដ្ឋាភិបាលបានទទួលស្គាល់នូវឥទ្ធិពលនៃការពង្រឹងយុទ្ធសាស្រ្តទីផ្សារ ដែលអាចរួមបញ្ចូលនូវអ្នកវិនិយោគ។ នៅឆ្នាំ២០០៧ រដ្ឋាភិបាលថ្នាក់កណ្តាលបានណែនាំនូវគ្រោងការសំណងបរិស្ថានមួយ (ជាទស្សនះបង្ហាញផ្លូវមួយទៅលើការងារសាកល្បងទាក់ទងទៅនឹងសំណងបរិស្ថាននៅឆ្នាំ២០០៧) ដែលមិនត្រឹមតែរួមបញ្ចូលសំណងទៅលើអ្នកផ្តល់សេវាកម្មបរិស្ថានប៉ុណ្ណោះទេ ប៉ុន្តែក៏បានគិតគូរផងដែរដល់ទម្រងផ្សេងៗទៀតនៃសំណង រួមមានអ្នកទទួលឥទ្ធិពលពីការបំពុលផងដែរ។

ប្រទេសឥណ្ឌូនេស៊ី បានបង្ហាញនូវគម្រោងគ្រប់គ្រងទីជម្រាលជាច្រើន ដែលប្រើសំណងលើសេវាកម្មបរិស្ថានជាគោលនយោបាយ។ ទាំងនោះរួមបញ្ចូលទន្លេស៊ីដានូ ដែលនៅតំបន់នោះបម្រែបម្រួលនៃការប្រើប្រាស់ដីបានបណ្តាលអោយកើតមានជាសំនឹកដី និងប៉ះពាល់ដល់គុណភាពទឹក។ ទៅតំបន់នោះក្រុមហ៊ុនផ្គត់ផ្គង់ទឹក បានចំណាយលើការថែទាំសេវាកម្មបរិស្ថាន និងបានបង្កើតស្ថាប័នអន្តរការីដើម្បីសម្របសម្រួលដល់ដំណើរការចំណាយនេះដោយគិតជាហិចតា។ នៅតំបន់លុមបុក ការចំណាយប្រហាក់ប្រហែលគ្នានេះដែរ គឺគិតគូរតាមរយៈអ្នកប្រើប្រាស់ទឹកនិមួយៗ ហើយស្ថាប័នអន្តរការីប្រើប្រាស់ថវិការដែលទទួលបានទាំងនោះសម្រាប់ការពារ និងដាំព្រៃឈើឡើងវិញ។

## សត្វព្រៃ និងរុក្ខជាតិដែលជានិមិត្តសញ្ញាតំណាងឲ្យប្រទេសកម្ពុជា




ប្រភព ៖httpchanroeun.files.wordpress.com200812animalsplantscambodia1.jpg

## ចំរៀងបទ ៖ សម្លេងព្រៃអន្ទរ

ចង្វាក់សារ៉ាវ៉ាន់ លំនាំបទ ស្រណោះផ្កាខ្ញុំ
រៀបរៀងដោយលោក គឹម សារិន អនុប្រធាននាយកដ្ឋានស្រាវជ្រាវ
និងអភិវឌ្ឍសហគមន៍តំបន់ការពារធម្មជាតិនៃក្រសួងបរិស្ថាន

១ -គួរឱ្យអាល័យ ព្រៃឈើធម្មជាតិ អើយធម្មជាតិ / បម្រើខ្ចីខ្ចាត ដល់គ្រប់មនុស្ស ជាតិមិនដែលនឿយណាយ ផ្តល់អុកស៊ីសែន ទ្រទ្រង់រាងកាយ អនុផលទាំងឡាយ ទេសចរណ៍សប្បាយ អារម្មណ៍ស្រស់ថ្លា ។

២-ព្រៃឈើផ្តល់ផល ដល់យើងគ្រប់គ្នា អើយគ្រប់គ្នា / រក្សាការពារ ខ្យល់ព្យុះព្យោមា ហូរច្រោះបាក់ដីសម្អាតជាតិពុល ក្នុងខ្យល់សព្វថ្ងៃ ភ្លៀងធ្លាក់ប្រពៃ ស្រោចស្រពលើដី ស្រូវស្រែចម្ការ។

R-ឥឡូវព្រៃថ្ងូរ ស្រែកយំអង្វរ ហាមកាប់បន្តនាំដល់គ្រោះភ័យ អាកាសឡើងក្តៅឥត ត្រាប្រណីរាំងស្ងួតរីងរៃ លើដីដំណាំ ក្រៀមស្វិតស្រពោន។

៣-យើងត្រូវរួមគ្នាការពារធម្មជាតិ អើយធម្មជាតិ/ សហការថែមទៀត ទាំងស្ថាប័នជាតិសហគមន៍មូលដ្ឋាន រក្សាព្រៃឈើ គង់វង្សថ្កើងថ្កាន ជាតិយើងនឹងបាន រីករាយសុខសាន្តតទៅរៀងអើយ។

# បញ្ជីពន្យល់ពាក្យ

| ពាក្យ | ការពន្យល់ |
|---|---|
| សមាហរណកម្ម | ការបញ្ចូលគ្នា ។ |
| ជីវៈចម្រុះ | ប្រភេទទាំងអស់ដែលមានជីវិតនៅលើផែនដីរួមមាន សត្វ រុក្ខជាតិ សត្វល្អិតគ្រប់ប្រភេទ និងមីក្រូសារពាង្គកាយ។ |
| សមភាព | គឺភាពស្មើគ្នាក្នុងការទទួលបានអ្វីមួយ។ |
| វិមជ្ឈការ | វិមជ្ឈការ គឺជាដំណើរការនៃការផ្ទេរការទទួលខុសត្រូវដើម្បីរៀបចំផែនការគ្រប់គ្រងធ្វើឱ្យការគ្រប់គ្រងនោះមានលក្ខណៈប្រសើរឡើង និងធ្វើការបែងចែកអំណាចពីរដ្ឋាភិបាល ថ្នាក់កណ្តាល និងភ្នាក់ងារទៅក្រសួង មន្ទីរ អាជ្ញាធរតំបន់ ឃុំ និងភូមិ ព្រមទាំងសហគមន៍។ |
| អភិរក្សធនធានធម្មជាតិ | ការគ្រប់គ្រង ការពារ និងថែរក្សាធនធានធម្មជាតិ និងបរិស្ថានសម្រាប់មនុស្សជំនាន់ក្រោយ ។ |
| អភិរក្សបម្រុងទុក | ការគ្រប់គ្រង ការពារ និងថែរក្សាធនធានធម្មជាតិ និងបរិស្ថានសម្រាប់គោលបំណងណាមួយ នៅពេលអនាគត ឬ សម្រាប់មនុស្សជំនាន់ក្រោយ។ |
| ការគ្រប់គ្រងធនធានប្រកប ដោយនិរន្តរភាព | គឺជាការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិសម្រាប់មនុស្សជំនាន់បច្ចុប្បន្ន និងមិនធ្វើឱ្យខូចខាតផលប្រយោជន៍ និងបន្សល់ទុកការខូចខាតបរិស្ថានសម្រាប់មនុស្សជំនាន់ក្រោយឡើយ ។ |
| មជ្ឈការ | សំដៅលើវិធីសាស្ត្រគ្រប់គ្រងពីថ្នាក់លើមកដល់ថ្នាក់មូលដ្ឋាន។ រដ្ឋាភិបាលជាអ្នកគ្រប់គ្រង និងជាម្ចាស់លើដំណើរការអ្វីមួយ។ |
| សហគ្រប់គ្រង | សហគ្រប់គ្រង គឺជាដំណើរការមួយដែលសហគមន៍មូលដ្ឋានរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធធ្វើការរួមគ្នាដើម្បីគ្រប់គ្រងធនធានធម្មជាតិ។ នេះមានន័យថាត្រូវតែមានការចែករំលែកអំណាចរវាង ស្ថាប័នរដ្ឋាភិបាល និងប្រជាពលរដ្ឋ។ សហគ្រប់គ្រងផ្តោតទៅលើដំណើរការគ្រប់គ្រងពីក្រោមឡើងលើ ជាជាងដំណើរការគ្រប់គ្រងពីលើចុះក្រោម។ |
| សេនេទិច | វិទ្យាសាស្ត្រដែលសិក្សាពីបែបបទនៃតំណពូជ។ |
| ទីជម្រាល | គឺជាផ្ទៃរងទឹកភ្លៀង ឬជាតំបន់ដែលមានទឹកនៅពីតំបន់ខាងលើទៅខាងក្រោម។ ទឹក ផ្លាស ទីតាមរយៈប្រព័ន្ធផ្លូវទឹកភ្លៀងទាំងនៅខាងលើដី និងក្រោមដី។ |
| អនុផលព្រៃឈើ | គឺជាផលិតផលដែលមិនមែនជាឈើហុប ដូចជា វល្លិ៍ អុស ឱសថ បន្លែផ្លែឈើជាដើម។ |
| តស៊ូមតិ | មាននិយមន័យផ្សេងៗច្រើនលើពាក្យនេះ។ ការតស៊ូមតិ គឺជាសកម្មភាពនានាដែលបាន គ្រោងទុកដើម្បីទាក់ទាញអារម្មណ៍របស់សហគមន៍ទៅនឹងចំណោតបញ្ហា និងឈានឆ្ពោះទៅរកអ្នកធ្វើគោលនយោបាយដើម្បីធ្វើសេចក្តីសម្រេចចិត្ត និងដើម្បីដោះស្រាយបញ្ហា។ ការតស៊ូមតិ គឺទាក់ទងទៅនឹងយុទ្ធសាស្ត្រផ្សេងៗ |

| | |
|---|---|
| | គ្នាក្នុងគោលបំណង បង្កើនឥទ្ធិពលសម្រាប់ការសម្រេចចិត្តនៅ កម្រិតថ្នាក់មូលដ្ឋាន ខេត្ត ជាតិ និងអន្តរជាតិ។ |
| សិទ្ធិធនធាន | គឺជាសំណុំនៃសិទ្ធិដែលពិពណ៌នាពីទំនាក់ទំនងរវាង ប្រជាពលរដ្ឋ និង ធនធានធម្មជាតិ។ សិទ្ធិគ្រប់គ្រងធនធានជួយបែងចែក រវាងម្ចាស់ធនធាន ដែលកាន់កាប់សិទ្ធិលើការគ្រប់គ្រងធនធានធម្មជាតិ និងអ្នកតាំងទីលំនៅដែល កាន់កាប់សំណុំនៃសិទ្ធិលើ ការគ្រប់គ្រងធនធានធម្មជាតិ។ |
| អភិបាលកិច្ចល្អ | គឺជាការគ្រប់គ្រង និងដឹកនាំដែលមានការចូលរួមយ៉ាងពេញលេញពីសំណាក់ អ្នកពាក់ព័ន្ធប្រកបដោយតម្លាភាព គណនេយ្យភាព និងការចែករំលែកអំណាច |
| ក្រុមប្រឹក្សាឃុំ-សង្កាត់ | ជាសមត្ថកិច្ចរដ្ឋបាលនៅថ្នាក់ទាបបំផុត ដែលកើតឡើងពីការបោះឆ្នោត និង ដែលមានអំណាចកសាងផែនការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិ ដោយនិរន្តរភាព។ តួនាទីពិតប្រាកដ របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ទាក់ទងនឹង សមត្ថកិច្ចបែបនេះនៅពុំទាន់ បញ្ជាក់បានច្បាស់ទាំង ស្រុងនៅឡើយទេ។ |
| ធនធានធម្មជាតិកើតឡើងវិញ | គឺជាធនធានដែលកើតឡើងវិញបានដោយខ្លួនឯងដោយរយៈពេលខ្លី ឬមាន ប្រភពមិនចេះអស់។ |
| ធនធានធម្មជាតិមិនកើតឡើងវិញ | សំដៅលើធនធានដែលចំណាយពេលវេលាយូរដើម្បីកកើតឡើងវិញ ឬ គឺជា ធនធានដែលអាចប្រើទៅអស់ដោយសារតែវាមាននៅក្នុងបរិមាណកំណត់ ណាមួយ។ ការប្រើប្រាស់ធនធាននេះ ប្រកបដោយនិរន្តរភាពអាចធ្វើទៅបាន តាមរយៈការកែច្នៃ និងការប្រើប្រាស់ធនធានជំរើស ផ្សេងទៀតដូចជាថាមពល រ៉ែប្រេងកាត។ |
| តម្លៃធនធានធម្មជាតិ | តម្លៃធនធានធម្មជាតិមានបីយ៉ាង គឺតម្លៃប្រើប្រាស់ តម្លៃជំរើស និងតម្លៃមិន ប្រើប្រាស់ |
| តម្លៃប្រើប្រាស់ | បង្ហាញពីការប្រើប្រាស់ធនធានធម្មជាតិដោយផ្ទាល់។ តម្លៃប្រើប្រាស់មានពីរ គឺតម្លៃ ប្រើប្រាស់ផ្ទាល់(ផលិតផល) តម្លៃប្រើប្រាស់ប្រយោល (សេវាកម្ម)។ |
| តម្លៃផ្ទាល់ | ជាតម្លៃនៃធនធានធម្មជាតិដែលផ្តល់ជាផលិតផល(ទំនិញ)។ |
| តម្លៃប្រយោល | ជាសេវាកម្មដែលផ្តល់ដោយធនធានធម្មជាតិ។ ឧទា. ព្រៃឈើជារបាំងខ្យល់ និងទាក់ទាញទឹកភ្លៀង។ |
| តម្លៃជម្រើស | បង្ហាញពីតម្លៃដែលមនុស្សផ្តល់អាទិភាពទៅលើលទ្ធភាពប្រើប្រាស់ធនធាននា ពេលអនាគត។ |
| តម្លៃមិនប្រើប្រាស់ | ជាតម្លៃដែលបង្ហាញពីទស្សនៈរួមមួយដែលប្រជាពលរដ្ឋមានឆន្ទៈចូលរួមការពារ ឬអភិរក្ស ធនធានដែលពួកគេនឹងមិនប្រើប្រាស |
| វិធីសាស្ត្រដែលមានការចូលរួម | សំដៅលើដំណើរការនៃការបង្កើនការចូលរួមរបស់អ្នកពាក់ព័ន្ធនានាជាពិសេស ផ្តោតទៅលើការ ចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋានក្នុងគម្រោង និងកម្មវិធី អភិវឌ្ឍន៍នានាដែលជា ញឹកញាប់មាន ការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល |

| | |
|---|---|
| | អ្នកជំនាញ ឬ ស្ថាប័នរដ្ឋាភិបាល ។ |
| ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ | ជាវិធីសាស្ត្រនៃសហគ្រប់គ្រងដែលពង្រឹងអំណាចសហគមន៍មូលដ្ឋានឱ្យចូលរួមយ៉ាងសកម្មក្នុងការអភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិដោយនិរន្តរភាពតាមរយៈ យុទ្ធសាស្ត្រនានារួម មានសហគមន៍ព្រៃឈើ សហគមន៍នេសាទ ការចូលរួមកសាងផែនការប្រើប្រាស់ដីធ្លី និងសហគមន៍គ្រប់គ្រងតំបន់ការពារធម្មជាតិ។ |
| សហគមន៍ | សំដៅលើក្រុមប្រជាពលរដ្ឋក្នុងឃុំមួយ ឬ ច្រើននៅក្នុងព្រះរាជាណាចក្រកម្ពុជា និងជា អ្នកដែលមានផលប្រយោជន៍រួមខាងសង្គម បរិស្ថាន វប្បធម៌ ប្រពៃណី និងសេដ្ឋកិច្ច និងជាអ្នកប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព ក្នុងតំបន់មួយ (ក្នុងកន្លែង ឬក្បែរកន្លែងដែលពួកគេរស់នៅ) សម្រាប់ទ្រទ្រង់ និងលើកកំពស់ជីវភាពរស់នៅ របស់ពួកគេ។ |
| ការរៀបចំសហគមន៍ | ជាដំណើរការមួយនៃការពង្រឹងអំណាចសហគមន៍ដោយខ្លួនឯងតាមរយៈការងារជាក់ស្តែងដើម្បី កំណត់តម្រូវការរបស់ខ្លួន និងដោះស្រាយបញ្ហារបស់ខ្លួនជាសមូហភាព។ |
| សហគមន៍នេសាទ | សំដៅលើ "ក្រុមមួយនៃប្រជាពលរដ្ឋដែលសហការគ្នាដោយស្មគ្រ័ចិត្តដើម្បីគ្រប់គ្រង អភិរក្ស អភិវឌ្ឍន៍ និងប្រើប្រាស់ធនធានជលផលដោយនិរន្តរភាព"។ សហគមន៍នេះ ការពារសិទ្ធិ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋអនុលោមតាមបទបញ្ញានានា ទាក់ទងនឹងវិស័យជលផល។ |
| សហគមន៍ព្រៃឈើ | ជាពាក្យដែលមានន័យទូលំទូលាយ ដោយរួមបញ្ចូលប្រព័ន្ធនានានៃការគ្រប់ព្រៃឈើដោយសហគមន៍ជនជាតិដើមភាគតិច ក៏ដូចជាកម្មវិធីនានា ដែលផ្តួចផ្តើមដោយសហគមន៍ ឬរដ្ឋាភិបាល។ បច្ចុប្បន្នពាក្យ សហគមន៍ព្រៃឈើត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ក្នុងការសំដៅលើទម្រង់ផ្សេងៗនៃការគ្រប់គ្រងព្រៃឈើដែលផ្អែក លើប្រជាពលរដ្ឋ។ |
| សហគមន៍តំបន់ការពារធម្មជាតិ | ត្រូវបានស្គាល់ថាជាការគ្រប់គ្រងតំបន់ការពារធម្មជាតិដោយមានការចូលរួមដែលជា ដំណើរការមួយសំដៅសម្រេចឱ្យបានស្ថានភាពឈ្នះ-ឈ្នះ ដែលផ្តល់ការអនុគ្រោះដល់អ្នកគ្រប់គ្រងធនធានក្នុងការសម្រេច គោលបំណងអភិរក្សជីវចម្រុះ និងដល់អ្នកប្រើប្រាស់ធនធានក្នុងការទ្រទ្រង់ជីវភាពរស់នៅ និងរក្សាតម្លៃវប្បធម៌ និងជំនឿ។ |
| សហគមន៍អេកូទេសចរណ៍ | បានអនុវត្តនៅកន្លែងដែលប្រជាពលរដ្ឋមូលដ្ឋាន មានអំណាចច្រើនក្នុងការត្រួតត្រា និងពាក់ព័ន្ធនៅក្នុងគម្រោងអេកូទេសចរណ៍ដើម្បីធានាថាផលប្រយោជន៍ភាគច្រើន បន្ទាប់ពីគម្រោងត្រូវប្រើប្រាស់នៅក្នុងសហគមន៍ដែលបានអនុវត្តគម្រោងនោះ។ |
| ការចូលរួមរៀបចំផែនការប្រើប្រាស់ដីធ្លី | ជាដំណើរការកសាងផែនការដែលផ្តួចផ្តើមនៅថ្នាក់ភូមិ ដែលនៅក្នុងនោះ អ្នកភូមិ និងអ្នកពាក់ព័ន្ធដទៃទៀតរួមគ្នារៀបចំផែនការសម្រាប់ការប្រើប្រាស់ |

| | |
|---|---|
| | ការពារ និងបែងចែកចំណែកដី ព្រៃឈើ ផ្ទៃដីកសិកម្ម និងទឹកនៅក្នុងព្រំប្រទល់នៃភូមិរបស់ខ្លួន។ |
| អេកូឡូស៊ី | វិទ្យាសាស្ត្រដែលសិក្សាអំពីទំនាក់ទំនងរវាងភាវៈរស់(សត្វ ឬរុក្ខជាតិ)ជាមួយនឹងមជ្ឈដ្ឋាន ជុំវិញ។ |
| ស្ថានប្រព័ន្ធ(ប្រព័ន្ធអេកូឡូស៊ី) | សំណុំសារពាង្គកាយមានជីវិតទាំងអស់ (សត្វ រុក្ខជាតិ និងមីក្រុប) រួមជាមួយមជ្ឈដ្ឋានមានជីវិត និងអន្តរកម្មរវាងសារពាង្គកាយមានជីវិតទាំងនោះជាមួយមជ្ឈដ្ឋានរបស់វា ដែលស្ថិតនៅក្នុងទី កន្លែងមួយកំណត់។ ឧទា. ប្រព័ន្ធអេកូឡូស៊ី ទឹកសាប ប្រព័ន្ធ អេកូឡូស៊ី ដីគោក។ល។ |
| យុទ្ធសាស្ត្រ | សំដៅលើការរៀបចំផែនការដើម្បីសម្រេចបាននូវគោលបំណងដែលបានគ្រោងទុក។ |
| អេកូ-ទេសចរណ៍ (ទេសចរណ៍ធម្មជាតិ) | សំដៅដល់ដំណើរកំសាន្តប្រកបដោយភាពទទួលខុសត្រូវនៅក្នុងតំបន់ធម្មជាតិ ដែលមានលក្ខណៈ អភិរក្សបរិស្ថាន និងកែលំអសុខុមាលភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ |
| តម្លាភាព | ភាពត្រឹមត្រូវ ស្មោះត្រង់ ដែលជាទូទៅពាក់ព័ន្ធនឹងភារកិច្ចទទួលខុសត្រូវលើកិច្ចការងារនានា ដែលជាផលប្រយោជន៍ស្របច្បាប់ចំពោះអ្នកពាក់ព័ន្ធនានា។ |
| គណនេយ្យភាព | ជាករណីកិច្ច និងសតិសម្បជញ្ញៈទទួលយកការទទួលខុសត្រូវ និងគិតពិចា-រណាយ៉ាងល្អិតល្អន់ចំពោះសកម្មភាពរបស់នរណាម្នាក់។ |
| បណ្ដាញការងារ | គឺជាក្រុមមនុស្ស ឬ ស្ថាប័នដែលស្ម័គ្រចិត្ត ធ្វើការផ្លាស់ប្ដូរព័ត៌មាន ឬធ្វើសកម្មភាពរួមគ្នា ហើយចាត់ចែងបង្កើតជាបណ្ដាញការងារនេះដោយខ្លួនឯង តែរក្សាឯករាជ្យភាពរៀងៗខ្លួន។ ឧទា. សម្ព័ន្ធភាព រឺជាសម្ព័ន្ធមិត្ត ដៃគូសមូហភាព។ |
| បរិបទ | ទម្រង់ ឬ បែបបទ ឬ ក្របខ័ណ្ឌសង្គមរបស់ក្រុមនានា និងប្រទេសនីមួយៗ។ |
| ឋានានុក្រម | លំដាប់លំដោយ ឬ របៀបពីធំមកតូច ឬ ពីតូចទៅធំ។ |
| សិទ្ធិប្រើប្រាស់ | ជាសិទ្ធិលើការប្រើប្រាស់ ដែលអាចកំណត់ដោយទម្លាប់នៅមូលដ្ឋាន កិច្ចព្រមព្រៀងរវាងគ្នា ឬ ចែងដោយអង្គភាពដទៃដែលមានសិទ្ធិកាន់កាប់។ សិទ្ធិបែបនេះអាចមាន ដែនកំណត់ត្រឹមប្រើប្រាស់ធនធានជាក់លាក់មួយចំនួនត្រឹមកម្រិតណាមួយនៃការទាញយកផល ឬតាមការប្រើប្រាស់ បច្ចេកទេសប្រមូលផលបែបណាមួយតែប៉ុណ្ណោះ។ |
| កម្មសិទ្ធិ | កិច្ចព្រមព្រៀងកំណត់ដោយសង្គម ដែលផ្ដល់អំណាចដល់បុគ្គល ឬ ក្រុមនានា និងទទួល ស្គាល់ដោយច្បាប់ ឬទម្លាប់ជាប្រពៃណីទាក់ទងជាមួយសិទ្ធិ និងកាតព្វកិច្ចមួយចំនួន អំពីកម្មសិទ្ធិ ការកាន់កាប់ ការចេញចូល និងប្រើប្រាស់ចំណែកដីណាមួយជាក់លាក់ ឬធនធាននានាដែល ពាក់ព័ន្ធនៅក្នុងចំណែក |

| | |
|---|---|
| | ដីនោះ (ដូចជាដើមឈើនានា ប្រភេទ រុក្ខជាតិ ទឹក រ៉ែ។ល។ ) |
| យុទ្ធសាស្ត្រចតុកោណ | យុទ្ធសាស្ត្រនេះសំដៅលើការបង្កើនកម្រិតលូតលាស់ ភាពមានការងារធ្វើ សមធម៌ និងប្រសិទ្ធភាព តាមរយៈការអនុវត្តផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ប្រចាំឆ្នាំលើកទី២ និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ។ នៅចំណុច ស្នូលនៃយុទ្ធសាស្ត្រនេះ គឺអភិបាលកិច្ចល្អដែលផ្តោតលើវិស័យបួនរួមមាន ការប្រឆាំងអំពើពុករលួយ ច្បាប់ និងតុលាការ រដ្ឋបាលសាធារណៈ និង វិមជ្ឈការ។ |
| កំណែទម្រង់គោលនយោបាយ វិស័យជលផល | ការកាត់ចេញដែនឡូត៍នេសាទប្រមាណ ៥៦ភាគរយ ដែលស្ថិតនៅក្រោម ការនេសាទ ជាលក្ខណៈពាណិជ្ជកម្មទៅជាដែននេសាទសហគមន៍ដែលជាការ ឆ្លើយតបរបស់រដ្ឋាភិបាលចំពោះកំណើនភាពតានតឹងរវាងអ្នកកាន់កាប់ ឡូត៍នេសាទ និងសហគមន៍ អ្នកនេសាទក្រីក្រនៅមូលដ្ឋាន។ |
| យុទ្ធសាស្ត្រជាតិកាត់បន្ថយភាព ក្រីក្រ | យុទ្ធសាស្ត្រនេះគូសបញ្ជាក់ពីសកម្មភាពមួយក្នុងចំណោម សកម្មភាពនានា ជាអាទិភាព សម្រាប់កាត់បន្ថយភាពក្រីក្រ គឺដើម្បីពង្រឹងស្ថាប័ន និងលើក កំពស់អភិបាលកិច្ចរួមទាំង កំណែទម្រង់លើការគ្រប់គ្រង ធនធានធម្មជាតិ (ដីធ្លី កសិកម្ម ព្រៃឈើ និងជលផល)។ |
| គោលនយោបាយវិមជ្ឈការរបស់ រដ្ឋាភិបាល | កម្មវិធីសិលារបស់រាជរដ្ឋាភិបាលបានជួយកសាងសមត្ថភាព សម្រាប់កសាង ផែនការអភិវឌ្ឍន៍តាមបែបវិមជ្ឈការ ដើម្បីឱ្យការធ្វើសេចក្តីសម្រេចភាគច្រើនបាន អនុវត្តនៅថ្នាក់ឃុំ ដែលនៅទីនោះគណៈកម្មការអភិវឌ្ឍន៍ឃុំ-សង្កាត់ ធ្វើសេចក្តី សម្រេចលើសកម្មភាពនៅមូលដ្ឋាន និងចាត់ចែងថវិកាឱ្យបានសមស្រប។ |
| ជីវម៉ាស់ | សំដៅទៅលើរូបធាតុណាដែលអាចដុតឆេះចេញជាចំហេះ ដូចជា អុស ធ្យូងជាដើម។ |
| លំហបៃតង | គឺសំដៅទៅលើគម្របរុក្ខជាតិ ឬព្រៃឈើដែលមានផ្ទៃពណ៌បៃតង |
| សេវាកម្ម | ការបម្រើ |
| តុល្យភាព | ភាពស្មើគ្នាដោយពិនិត្យមើល |
| ធរណីកាល | អាយុ ឬរយៈពេលនៃផែនដី |
| ចំណេះដឹងជាមូលដ្ឋាន | ចំណេះដឹងកម្រិតដំបូង មិនទាន់ស៊ីជម្រៅ។<br>ចំណេះដឹងនេះជាមូលសម្រាប់ចាប់យក<br>ចំណេះដឹងខ្ពស់ជាងនេះដែលផ្តោតលើការវិភាគ។ |
| គុណភាពនៃជីវិត | កម្រិតនៃការរស់នៅដែលមិនទទួលរងផលប៉ះពាល់ពីបរិស្ថាន។ |

# ឯកសារយោង

Carson, T. (1998). Community based natural resource management in Cambodia in Environment: Concepts and Issues - A Focus on Cambodia compiled by O'Brien N. 1999

CBNRM Learning Initiative/WWF. (2003). A Workshop Proceeding Report on Community Based Natural Resource Management in Cambodia, Phnom Penh, Cambodia

CCC (2005). NGO Good Practice Principles Pilot Project (NGO GPP) Newsletter -February

Department of Environmental Science (2005). Aquatic Resource Management Course. Royal University of Phnom Penh, compiled by Seak Sophat

Department of Environmental Science (2005). Integrated Natural Resource Management and Planning Course, Royal University of Phnom Penh, compiled by Seak Sophat

Henderson, D. (2005). Improving Forest Governance in Cambodia: The roles of Community Forestry in the Development of Community Based Natural Resource Management (CBNRM in Cambodia) - Selected paper on concepts and issues, Community Based Natural Resource Management Learning Initiative, Cambodia.

ICLARM and IFM (1998). Analysis of Co-Management Arrangement in Fisheries and related Costal Resources - A research framework

IDRC website on sustainable development in www.idrc.ca/en/ev

Keen, M. and Lal, P. (2002). Creating supportive frameworks for community based resource management in Development Bulletin No. 58 July 2002 Environmental sustainability and poverty reduction: Pacific Issues

Kupczyk-Romanczuk, G. (2002). Environmental Words Dictionary

Mak, S., Heun, H. and Pen, R. (2004). Decentralization and Natural Resource Management – Implication of Cambodian Decentralization on Natural Resource Management and Livelihoods. Fisheries Action Coalition Team, Phnom Penh, Cambodia

MoE, BPAMP, World Bank and GEF. (2005). Participatory Development of Management Plans for Protected Areas in Cambodia, Phnom Penh, Cambodia

Morrison, R.J and Kaly, L.U. (2002). Low cost technology for monitoring sustainable development in Development Bulletin No. 58 July 2002 Environmental sustainability and poverty reduction: Pacific Issues

MRC/GTZ (2005). Natural Resource and Governance: Incentives for sustainable resource use in the Mekong River Basin.

O'Brien, N. (1999). Environment: Concepts and Issues - A focus on Cambodia

Suzuki, R. (2005). The Intersection of Decentralization and Conflict in Natural Resource Management: Cases from Southeast Asia. International Development Research Centre

Rock, F [ed] 2001. Participatory Land Use Planning - PLUP in rural Cambodia. Manual for Government staff and development workers. Ministry of Land Management, Urban Planning and Construction, Phnom Penh.

Thay, S (2002). Concept of fisheries co-management in Cambodia context: A case study in fishing lots # 3and #6, Siem Reap Province, Cambodia

Thyl de Lopez, Thanakvaro, (2004). Resource Degradation, property rights, social capital and community forestry in Cambodia. Cambodian Research Centre for Development (CRCD), Kingdom of Cambodia

Tietenberg, T. (2003). Environmental Economics and Policy (fourth edition). Colby College. Pearson Addison Wesley: United States of America

Tin, P. (1998). Environmental Words Dictionary

Tovar, P. et al (2003). City of Kirkland: Natural Resource Management Plan

WWF (2005): WWF Cambodia Programme Fact sheet

Van Acker, F., 2010. Free Riders and Social Fences: Common property, collective and decentralized natural resource management in Cambodia. Phnom Penh: The Learning Institute and Administrative Reform and Decentralisation Program (ARDP) of German Development Cooperation (implemented by GTZ)

Pernille, 2006. Community based natural resource management in Cambodia.

វិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (CBNRM Learning Institute): CBNRM នៅកម្ពុជា : អត្ថបទជ្រើសរើសស្ដីពីទស្សនទាន និងបទពិសោធន៍ ភាគទី១ ឆ្នាំ ២០០៥ ។

វិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (CBNRM Learning Institute) : និន្នាការ បញ្ហាប្រឈម និងគំនិតច្នៃប្រឌិតថ្មីៗ : ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ នៅកម្ពុជា ភាគទី ២ ឆ្នាំ ២០០៩ ។

រូបភាពនៅគ្របខាងមុខនៃសៀវភៅផ្ដល់ដោយលោក គីម សារិន ។

ក្រសួងមហាផ្ទៃ សៀវភៅណែនាំស្ដីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ខែមករា ឆ្នាំ២០០៩ ។ របាយការណ៍បណ្ដុះបណ្ដាលក្នុងតំបន់ប្រទេសស្ដីពីគោលការណ៍សុវត្ថិភាព ខែមីនា ឆ្នាំ ២០០៩ រៀបចំដោយក្រុមគាំទ្រកម្មវិធីនៃគណៈកម្មាធិការសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

សុវត្ថិភាពបរិស្ថានចងក្រងដោយលោកស្រី ពុំ វិចិត្រ ទីប្រឹក្សាបរិស្ថាននៃគម្រោងអភិវឌ្ឍន៍ជនបទតំបន់ទំនាបបឹងទន្លេសាប (TSLRDP) ឆ្នាំ ២០១០ ។








**វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល**

ផ្លូវលេខ៣០ ផ្ទះលេខ៩ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន

ភ្នំពេញ កម្ពុជា ប្រអប់សំបុត្រលេខ ២៥០៩

ទូរស័ព្ទ ៨៥៥ (0) ២៣ ៩៩៤ ៩៣៥

ទូរសារ ៨៥៥ (0) ២៣ ២២៤ ១៧១

អ៊ីម៉ែល៖ info@learninginstitute.org

គេហទំព័រ៖ www.learninginstitute.org



២០១២ រក្សាសិទ្ធិគ្រប់យ៉ាង



*"សៀវភៅបណ្តុះបណ្តាលនេះត្រូវបានផលិតក្រោមជំនួយសហភាពអឺរ៉ុប។ ខ្លឹមសារដែលបានបង្ហាញក្នុងសៀវភៅនេះជាការទទួលខុសត្រូវរបស់វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ។"*